# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថាន
# មីក្រូហិរញ្ញវត្ថុអម្រឹត

PROCEDURES FOR RECEIVING DEPOSITS FROM AMRET
MICROFINANCE INSTITUTION

## ជំនាញ ហិរញ្ញវត្ថុ និងធនាគារ


**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

PROCEDURES FOR RECEIVING DEPOSITS FROM AMRET MICROFINANCE INSTITUTION

គ្រូណែនាំ៖ សៀវ សុធា

ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទៈ នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សៀវ សុជា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធាន
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធានរង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ ហិរញ្ញវត្ថុ និង ធនាគារនៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាហិរញ្ញវត្ថុ និង ធនាគារ ជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញហិរញ្ញវត្ថុ និង ធនាគារ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យ វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា ។ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ឃុយ ឡៃហ៊ីម**
ID:B22/1030



**បឿន ចាន្ទា**
ID:B22/2166



**ស៊ុម សុភក្តិ**
ID:B22/687



**ប៉េង ស៊ូអ៊័រ**
ID:B22/2604



**ឆា រិទ្ធី**
ID:B22/433

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញហិរញ្ញវត្ថុ និងធនាគារ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សកលវិទ្យាធិកានៃសកលវិទ្យាល័យវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះគ្រូ **សៀង សុធា** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ/ខ្ញុំបាទ ជានិស្សិតបរិញ្ញាបត្រជំនាញហិរញ្ញវត្ថុនិងធនាគារ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២ ៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត. ខែ.កត្តិក. ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី.២៩. ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

ជា រិទ្ធី

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ឆ្លងតាមការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើនខែកន្លងមក កាលពីមុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតគ្រាន់តែជាប្រភេទអង្គការក្រៅរដ្ឋាភិបាលតែប៉ុណ្ណោះ បន្ទាប់មកបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា "ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ" នៅឆ្នាំ២០០១ ដោយសារមានការខិតខំប្រឹងប្រែងជាខ្លាំង ទើបធ្វើឱ្យគ្រឹះស្ថានទទួលបានជោគជ័យលើវិស័យហិរញ្ញវត្ថុនេះ និងបានវិវត្តន៍ខ្លួនយ៉ាងឆាប់រហ័ស ហើយទាន់សម័យកាលថែមទាំងមានការគាំទ្រពីសំណាក់ប្រជាជនកម្ពុជាព្រមទាំងរដ្ឋាភិបាលទៀតផង។ អម្រឹតមានសេវាកម្មហិរញ្ញវត្ថុជាច្រើន មានទាំងឥណទាន សេវាទទួលប្រាក់បញ្ញើសម្រាប់បម្រើជូនដល់ប្រជាជនកម្ពុជា ដែលជាការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើន ប្រជាជនមានជីវភាពធូរធារជាងមុន ម្យ៉ាងវិញទៀតជួយធ្វើឱ្យសេដ្ឋកិច្ចប្រទេសជាតិដើរទៅមុខ មិននៅត្រឹងមួយកន្លែងដោយប្រមូលទុនពីអ្នកដែលសល់ទុន ទៅឱ្យអ្នកដែលខ្វះទុន។ ជាពិសេសនោះគឺជួយគាំទ្រទៅដល់ការសិក្សា បង្កើនធនធានមនុស្សនៅប្រទេសកម្ពុជាឱ្យសម្បូរបែប និងធ្វើឱ្យប្រជាជនយើងសម្បូរទៅដោយអ្នកដែលមានចំណេះដឹងច្រើន។ ដោយសារតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានផលិតផល និងសេវាកម្មសម្បូរបែប ជាពិសេសសេវាប្រាក់បញ្ញើជាហេតុនាំឱ្យក្លាយទៅជាប្រភពចំណូលមួយដល់សំខាន់សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ការប្រើប្រាស់សេវាប្រាក់បញ្ញើ មានអត្រាកើនឡើងជាលំដាប់ និងមានការប្រកួតប្រជែងគ្នាខ្ពស់។

គោលបំណងនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើប្រធានបទ "នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត" ដើម្បីស្វែងយល់បន្ថែមទៀតពីរបៀបដាក់ប្រាក់ ប្រភេទនៃសេវាកម្មប្រាក់បញ្ញើ ប្រភេទគណនីប្រាក់បញ្ញើ អត្ថប្រយោជន៍ពីប្រភេទគណនីនីមួយៗ រួមទាំមអត្រាការប្រាក់ដែលទទួលបានក្នុងការដាក់ប្រាក់បញ្ញើពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។

ក្រុមយើងខ្ញុំសូមផ្តល់ជាមតិយោបល់ និងអនុសាសន៍មួយចំនួនក្នុងន័យស្ថាបនាកែលម្អនៅចំណុចខ្វះខាតទាំងនោះដើម្បីឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតទទួលបានការដាក់ប្រាក់បញ្ញើពីអតិថិជនកាន់តែច្រើន និងមានការរីកចម្រើនជាងមុន។ ប្រសិនជាអាចគណនីក្មេងឆ្លាត អាចដាក់ប្រាក់សន្សំចាប់ពីថ្នាក់ក្រោមឧត្តមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា និងមានបែងចែកជាកញ្ចប់គឺកញ្ចប់សម្រាប់ថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យទៀតនោះវានឹងជួយសម្រួលនូវកត្តាជីវភាព និងកាត់បន្ថយអត្រានៃការបាត់បង់ការសិក្សា។ ចំណែកឯគណនីប្រាថ្នាគួរតែបង្កើនការផ្សព្វផ្សាយទាក់ទងនឹងគណនីនេះ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបានតាមរយៈបណ្តាញសង្គម ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដើម្បីឱ្យអតិថិជនយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍នៃគណនីប្រាថ្នា។

# មាតិកា


ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធ ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

 ១.៤.១ ទំហំដែនកំណត់ ........ ២

 ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

២.១ លក្ខណៈទូទៅនីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........ ៤

 ២.១.១ និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........ ៤

 ២.១.២ ប្រវត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........ ៤

 ២.១.៣ ប្រភេទគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........ ៥

២.២ សេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........ ៥

 ២.២.១ និយមន័យប្រាក់បញ្ញើ ........ ៥

 ២.២.២ ប្រវត្តិប្រាក់បញ្ញើ ........ ៦

 ២.២.៣ ប្រភេទប្រាក់បញ្ញើ ........ ៦

២.៣ នីតិវិធីក្នុងការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........ ៧

 ២.៣.១ និយមន័យនីតិ ........ ៧

 ២.៣.២ ប្រវត្តិនីតិ ........ ៧

 ២.៣.៣ មុខងារនីតិ ........ ៨

## ជំពូកទី៣
## នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

៣.១ ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ....................................................................... ៩
៣.១.១ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ....................................................................... ៩
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ..................... ១០
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ........... ១០
៣.២ សេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ....................................................... ១២
៣.៣ ហានិភ័យប្រឈមនៃសេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត........................... ២០

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង......................................................................................... ២៤
៤.២ ការវិភាគលើចំណុចខ្សោយ ....................................................................................... ២៤

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្ដីសន្និដ្ឋាន ................................................................................................ ២៦
៥.២ ការផ្ដល់អនុសាសន៍ ............................................................................................. ២៦
**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថា សេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើន ដោយទទួលលទ្ធផលដ៏ល្អប្រសើរ។ បន្ទាប់ពីមានសុខសន្តិភាពផ្នែកនយោបាយ និងសណ្តាប់ធ្នាប់សង្គមមកប្រតិបត្តិការនៃវិស័យហិរញ្ញវត្ថុមានការរីកលូតលាស់គួរឱ្យកត់សម្គាល់ ហើយបានបម្រើផលប្រយោជន៍ និងលើកកម្ពស់ជីវភាពប្រជាជនប្រកបដោយប្រសិទ្ធភាព។ វិស័យហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ក៏ត្រូវបានរំលេចឡើងតាមរយៈការផ្តល់សេវាកម្មយ៉ាងសម្បូរបែបដល់វិនិយោគិនទាំងក្នុងនិងក្រៅប្រទេស។ បន្ទាប់ពីមានការកែទម្រង់សេដ្ឋកិច្ច វិស័យធនាគារបានដើរតួនាទីជាស្នូលសំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ឆ្ពោះទៅរកការកាត់បន្ថយនៃភាពក្រីក្រ និងលើកកម្ពស់ជីវភាពប្រជាជនស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ យើងសង្កេតឃើញថា មានវិនិយោគិនទាំងក្នុងនិងក្រៅប្រទេសធ្វើការវិនិយោគគ្រប់វិស័យក្នុងប្រទេសកម្ពុជា។

ទន្ទឹមនឹងការរីកចម្រើនលើគ្រប់វិស័យនេះផងដែរ ប្រព័ន្ធធនាគារត្រូវបានពង្រឹងនិងធ្វើកំណែទម្រង់ជាបន្តបន្ទាប់ដើម្បីឱ្យសាធារណៈជនទទួលបានទំនុកចិត្តកាន់តែខ្ពស់ទៅលើប្រតិបត្តិការរបស់ខ្លួន តាមរយៈការផ្តល់សេវាកម្មកាន់តែច្រើនពីគ្រឹះស្ថានរួមមានដូចជា សេវាឥណទាន សេវាប្រាក់បញ្ញើ សេវាប្តូរប្រាក់ សេវាទូទាត់សាច់ប្រាក់ សេវាផ្ទេរប្រាក់ក្នុង និងក្រៅប្រទេសព្រមទាំងសេវាផ្សេងៗជាច្រើនទៀត ដើម្បីជួយសម្រួល និងឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនដែលត្រូវការដើមទុន ជាពិសេសគឺអ្នកវិនិយោគ។ អាស្រ័យនេះហើយទើបបណ្តាលធនាគារ និងគ្រឹះស្ថានទាំងអស់ខិតខំរកយុទ្ធសាស្ត្រ និងបច្ចេកវិទ្យាទំនើបៗ ដើម្បីប្រជែងក្នុងគោលបំណង ទាក់ទាញអតិថិជនទទួលប្រាក់បញ្ញើឱ្យមានចំនួនកាន់តែច្រើនឡើងជាងធនាគារ និងគ្រឹះស្ថានដទៃទៀត។

ជាក់ស្តែងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត គឺជាគ្រឹះស្ថានមួយដែលបម្រើសេវាកម្មជូនអតិថិជនមិនថានៅតាមទីប្រជុំជន ឬជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតខិតខំបង្កើតនូវសេវាកម្មថ្មីៗ ជាពិសេសសេវាប្រាក់បញ្ញើក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនឱ្យមានជីវភាពធូរធារ។ ដោយមើលឃើញពីភាពរីកចម្រើនទៅលើ សេវាកម្មទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុម្រឹត ទើបក្រុមរបស់យើងខ្ញុំជ្រើសរើសប្រធានបទស្តីពី "**នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត** " យកមកធ្វើការស្រាវជ្រាវ និងរៀបចំជាសារណា សម្រាប់ទុកឱ្យនិស្សិតជំនាន់ក្រោយបានសិក្សាស្រាវជ្រាវ
បន្ត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យវិស័យនេះ រីកចម្រើនប្រកបដោយប្រសិទ្ធភាពផ្តល់ទំនុកចិត្តដល់អតិថិជន និងវិនិយោគិន ធនាគារជាតិបានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ក៏ដូចជាបង្កើតនិងរឹតបន្តឹងច្បាប់នានាជាបន្តបន្ទាប់។ ដើម្បីឱ្យយល់កាន់តែច្បាស់ពីសេវាប្រាក់បញ្ញើយើងបានយកសំណួរមកចោទសួរដូចខាងក្រោម ៖
១.តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត មាននូវប្រភេទសេវាកម្មអ្វីខ្លះដែលអាចបម្រើជូនដល់អតិថិជនបាន ?

២.តើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតអាចប្រឈមទៅនឹងហានិភ័យអ្វីខ្លះពីសេវាប្រាក់បញ្ញើ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទខាងលើនេះក្រុមយើងខ្ញុំបានធ្វើការសិក្សាផ្ទាល់ទៅលើ នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។ ចំណែកគោលបំណងនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺដើម្បីពង្រីកចំណេះដឹង និងបទពិសោធន៍ពីការប្រៀបធៀបរវាងទ្រឹស្តីទៅ និងការអនុវត្តជាក់ស្តែងតាមរយៈការចុះកម្មសិក្សារឈ្វេងយល់ពីចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ប្រភេទប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- លក្ខខណ្ឌនៅក្នុងការដាក់ប្រាក់បញ្ញើ
- ប្រភេទរូបិយប័ណ្ណដែលបានដាក់បញ្ញើ
- អត្រាការប្រាក់តាមប្រភេទប្រាក់បញ្ញើនីមួយៗ
- ហានិភ័យដែលប្រឈមពីសេវាកម្មប្រាក់បញ្ញើ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតមានបណ្តាញសាខាជាច្រើនគ្រប់ដណ្តប់ទូទាំងប្រទេស ពេលវេលានៃការស្រាវជ្រាវមានកំណត់ ដូច្នេះក្រុមខ្ញុំបាទ/នាងខ្ញុំ សូមលើកយកតែផ្នែកមួយនៅក្នុងប្រតិបត្តិការជាច្រើនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ដែលមានទីស្នាក់ការកណ្តាលនៅខណ្ឌទួលគោកដែលមានទីតាំងផ្ទះលេខ៨០ ផ្លូវលេខ៣១៥ ភូមិ៧ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទៅលើនីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត មកធ្វើការស្រាវជ្រាវតែប៉ុណ្ណោះ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ប្រធានបទទាក់ទងទៅនឹង នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ក្រុមរបស់ខ្ញុំបាទ/នាងខ្ញុំ បានធ្វើការប្រមូលទិន្នន័យដែលបានកើតមានមកបង្ហាញនៅក្នុងឆ្នាំ២០២៤ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវ ត្រូវបានប្រើវិធីសាស្ត្រគុណភាពស្វ័យប្រវត្តិ (Qualitative methods) ដោយផ្តោតជាចម្បងលើការវិភាគទិន្នន័យបន្ទាប់បន្សំបានមកពីប្រភពដូចជា គេហទំព័រ បណ្តាញសង្គម និងឯកសារនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពីប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។

**សម្រាប់សំណួរទី១៖** ត្រូវបានប្រមូលតាមគុណវិស័យបានមកពីប្រភពគេហទំព័រមួយគឺ amret.com.kh និងឯកសារនានា ក្នុងគោលបំណងបញ្ជាក់ពីប្រភេទសេវាកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។

**សម្រាប់សំណួរទី២ ៖** ត្រូវបានប្រមូលតាមគុណវិស័យបានមកពីប្រភព បណ្តាញសង្គមនានា ដើម្បីបញ្ជាក់ពីហានិភ័យប្រឈមពីសេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការនាំមកនូវភាពរីកចម្រើនដល់និស្សិតជាច្រើនក្នុងការផ្លាស់ប្តូរពួកគេឱ្យយល់ដឹងពីសកម្មភាពក្នុងសង្គម ការទំនាក់ទំនងនិងប្រតិបត្តិការមួយចំនួននៅក្នុងពេលបច្ចុប្បន្ននេះ។ សារៈសំខាន់នៃការស្រាវជ្រាវនេះគឺផ្តល់នូវចំណេះដឹងដល់ក្រុមយើងខ្ញុំដូចជា ៖

- យល់ដឹងពីប្រភេទប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យល់ដឹងពីលក្ខខណ្ឌ និងប្រភេទរូបិយប័ណ្ណដែលបានដាក់បញ្ញើក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យល់ដឹងពីអត្រាការប្រាក់តាមប្រភេទប្រាក់បញ្ញើនីមួយៗ
- បង្កើចំណេះដឹងបន្ថែម ទៅលើការសិក្សាស្រាវជ្រាវ និងការសរសេរសារណា
- ធ្វើឱ្យនិស្សិតជាច្រើនមើលឃើញពីគុណតម្លៃនៃការសិក្សាស្រាវជ្រាវ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ យើងខ្ញុំបានកំណត់ និងបែងចែកជាសកម្មភាពទៅតាមដំណាក់កាលនីមួយៗដូចខាងក្រោម ៖

- **ជំពូកទី១ សេចក្តីផ្តើម៖** បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណង មូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ដែនកំណត់និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវ។
- **ជំពូកទី២ រំលឹកទ្រឹស្តី៖** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលលើកយកមកធ្វើការសិក្សាស្រាវជ្រាវ។
- **ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ៖** បង្ហាញពីស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត គោលការណ៍ក្នុងនីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។
- **ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ៖** ធ្វើការវិភាគនឹងស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទ។
- **ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖** សន្និដ្ឋានទៅលើចំណុចខ្លឹមសំខាន់ៗដែលមាននៅក្នុងអត្ថបទ និងផ្តល់អនុសាស៍លើចំណុចដែលខ្វះខាតដើម្បីធ្វើការកែតម្រូវ។

# ជំពូកទី២

# នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ២.១ លក្ខណៈទូទៅនីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ២.១.១ និយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖** គឺជាគ្រឹះស្ថានដែលផ្តត់ផ្គង់ប្រាក់កម្ចី ប្រាក់សន្សំ និងសេវាហិរញ្ញវត្ថុទៅដល់តម្រូវការរបស់ប្រជាពលរដ្ឋ។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាស្ថាប័នដែលបង្កើតឡើងជាពិសេសដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍អាជីវកម្ម និងការពង្រឹងសហគមន៍ ជាពិសេសម្ចាស់អង្គភាពអាជីវកម្មខ្នាតតូច។[1]
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាស្ថាប័នហិរញ្ញវត្ថុដែលផ្តល់សេវាកម្មហិរញ្ញវត្ថុ ដល់បុគ្គលដែលមានចំណូលទាប និងក្រុមដែលមិនមានលទ្ធភាពលក្នុងការប្រើប្រាស់ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ស្រដៀងទៅនឹងធនាគារតូចៗដែរ ប៉ុន្តែពួកគេបម្រើប្រជាជនដែលខ្វះខាតផ្នែកសេដ្ឋកិច្ច។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាអ្នកផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ដែលមានផ្តល់សេវាកម្មដូចជាសេវាប្រាក់សន្សំ ប្រាក់បញ្ញើ ប្រាក់កម្ចីខ្នាតតូច និងខ្នាតមធ្យមដល់ប្រជាជនដែលពួកគាត់អាចយកទៅប្រើប្រាស់តាមតម្រូវការដែលពួកគាត់ចង់បាន។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាស្ថាប័នហិរញ្ញវត្ថុដែលផ្តល់សេវាឥណទាន សេវាសន្សំនិងសេវាហិរញ្ញវត្ថុដទៃទៀតដល់អ្នកក្រ។ សេវាហិរញ្ញវត្ថុត្រូវការដោយអ្នកក្រ រួមមាន មូលធនចល័តឥណទានអ្នកប្រើប្រាស់ មូលនិធិសោធននិវត្តន៍ ការធានារ៉ាប់រង និងសេវាផ្ទេរប្រាក់។
- **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** គឺជាអង្គភាពមួយប្រភេទ ដែលផ្តល់សេវាហិរញ្ញវត្ថុ ដល់ប្រជាពលរដ្ឋទាំងឡាយ។ ភាគច្រើននៃអង្គភាពទាំងនេះ ផ្តល់ឥណទានខ្នាត់តូចបំផុតនិងទទួលប្រាក់បញ្ញើសន្សំតិចតួច ពីអ្នកខ្ចីផ្ទាល់របស់ខ្លួន មិនមែនពីសាធារណជនទេ។[2]

### ២.១.២ ប្រវត្តិគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានបង្កើតឡើង នៅក្នុងទសវត្សរ៍ឆ្នាំ1970 នៅពេលដែលអង្គការដូចជា Grameen Bank of Bangladesh ជាមួយអ្នកត្រួសត្រាយមីក្រូហិរញ្ញវត្ថុ Mohammad Yunus ដែលជាកន្លែងចាប់ផ្តើម និងបង្កើតឧស្សាហកម្មទំនើបនៃមីក្រូហិរញ្ញវត្ថុ។ អ្នកត្រួសត្រាយផ្លូវម្នាក់ទៀតនៅក្នុងវិស័យនេះគឺ Akhtar Hameed Khan នៅពេលនោះរលកថ្មីនៃគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុបានណែនាំការច្នៃប្រឌិតថ្មីៗជាច្រើនទៅក្នុងវិស័យនេះ។ សហគ្រាសត្រួសត្រាយជាច្រើន បានចាប់ផ្តើមពិសោធន៏ជាមួយការផ្តល់ប្រាក់កម្ចីដល់ប្រជាជនដែលខ្វះខាត។ មូលហេតុចម្បងដែល មីក្រូហិរញ្ញវត្ថុមានចុះកាលបរិច្ឆេទក្នុទសវត្សរ៍ឆ្នាំ 1970 គឺថាកម្មវិធីអាចបង្ហាញថាមនុស្សអាចពឹងផ្អែកលើការសងប្រាក់កម្ចីរបស់ពួកគេ ហើយវាអាចផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រតាមរយៈសហគ្រាសដែលមានមូលដ្ឋានលើទីផ្សារដោយគ្មានការឧបត្ថម្ភធន។ បន្ថែមពីលើនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ដើម្បីផ្តល់សេវាកម្មហិរញ្ញវត្ថុដល់បុគ្គលដែល

---

[1] Microfinance institution. *គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ. Retrieved from* June, 12 2025 from https://developers.bri.co.id/en/node/51155

[2] Khem Sarith. (October 2016). *ការគ្រប់គ្រងហិរញ្ញវត្ថុអន្តរជាតិ. Retrieved from* June, 12 2025 from https://khemsarith.wordpress.com/2016/10/

មានចំណូលទាបដែលមិនមានលទ្ធភាពប្រើប្រាស់សេវាធនាគារបែបប្រពៃណី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនធ្វើការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលប្រជាជនភាគច្រើនមិនមានធនាគារហើយរស់នៅដោយប្រាក់ចំណូលទាបបំផុត។ ស្ថាប័នទាំងនេះផ្តល់ប្រាក់កម្ចីខ្នាតតូច គណនីសន្សំ និងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀតដើម្បីជួយជនក្រីក្រនិងមិនមានធនាគារឱ្យក្លាយជាអ្នកមានហិរញ្ញវត្ថុដោយខ្លួនឯង។ជាធម្មតាពួកគេដំណើរការក្រោមគោលការណ៍នៃទំនួលខុសត្រូវសង្គមហើយមានគោលបំណងផ្តល់ជូនមិនត្រឹមតែសេវាកម្មហិរញ្ញវត្ថុប៉ុណ្ណោះនោះទេប៉ុន្តែក៏មានការអប់រំការបណ្តុះបណ្តាល និងការគាំទ្រដល់អតិថិជនរបស់ពួកគេផងដែរ។

### ២.១.៣ ប្រភេទគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានគេបែងចែកជា២ប្រភេទគឺៈ

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ។
  - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៖ មានឯកទេសក្នុងការផ្តល់សេវាដូចជា ផ្តល់កម្ចីនិងទទួលប្រាក់បញ្ញើសម្រាប់ក្រុមឬបុគ្គលក្រីក្រនិងមានចំណូលទាប រួមទាំងសហគ្រាសធន់តូច។
  - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៖ គឺជាមីក្រូហិរញ្ញវត្ថុដែលបានផ្តល់ជូនចំពោះការកម្ចីសម្រាប់អតិថិជនតែប៉ុណ្ណោះ ប៉ុន្តែមិនទទួលប្រាក់បញ្ញើឡើយដោយសារតែពួកគេមិនហ៊ានដាក់ទុនលើផ្នែកបញ្ញើព្រោះការបញ្ញើអាចមានហានិភ័យខ្ពស់សម្រាប់ស្ថាប័នដែលទើបនិងបើក ឬមានអាយុកាលខ្លីពេក។

## ២.២ សេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ២.២.១ និយមន័យប្រាក់បញ្ញើ

- **ប្រាក់បញ្ញើ** ៖ ជាប្រភេទមូលធនដ៏សំខាន់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលរួមមានប្រាក់បញ្ញើសន្សំនិងបញ្ញើមានកាលកំណត់។
- **ប្រាក់បញ្ញើ** ៖ គឺជាប្រភេទគណនី ដែលលោកអ្នកអាចធ្វើការសន្សំប្រាក់ ក្នុងរយៈពេលកំណត់ណាមួយ ដោយទទួលបានអត្រាការប្រាក់ខ្ពស់ជាងគេ បើប្រៀបធៀបទៅនឹងគណនីសន្សំទូទៅ។ [3]
- **ប្រាក់បញ្ញើ** ៖ ជាសាច់ប្រាក់ ដែលអ្នកបានបង់ទៅក្នុងគណនីមីក្រូហិរញ្ញវត្ថុ ឬគណនីសន្សំរបស់លោកអ្នកបន្ទាប់នឹងមានទំនួលខុសត្រូវក្នុងការរក្សាទុកប្រាក់ដោយសុវត្ថិភាព និងសងប្រាក់អ្នកវិញតាមលក្ខខណ្ឌដែលអ្នកបានយល់ព្រមសម្រាប់គណនីនោះ។
- **ប្រាក់បញ្ញើ** ៖ ជាសាច់ប្រាក់ ឬជាមូលប័ត្រដែលអតិថិជនសល់ទុកយកមកផ្ញើនៅមីក្រូហិរញ្ញវត្ថុដើម្បីធ្វើការចុះបញ្ជីរបស់អតិថិជនហើយប្រាក់បញ្ញើទាំងនោះ គឺជាបំណុលចំពោះមីក្រូហិរញ្ញវត្ថុដើម្បីឱ្យធ្វើការសងទៅអតិថិជនទាំងនោះវិញក្នុងទម្រង់ដែលបានកំណត់ទុកមុន។
- **ប្រាក់បញ្ញើ** ៖ គឺជាសាច់ប្រាក់ជ ឬជារូបិយបត្រដែលអតិថិជនសល់ទុកយកផ្ញើនៅធនាគារដើម្បីឱ្យមីក្រូហិរញ្ញវត្ថុធ្វើការចុះបញ្ជីរបស់គេ ហើយប្រាក់បញ្ញើទាំងនោះ គឺជាប់បំណុល

[3] Developers. (2023). *ប្រាក់បញ្ញើ*. Retrieved June, 13 2025 from https://developers.bri.co.id/en/node/51155

ធនាគារដើម្បីធនាគារត្រូវធ្វើការសងទៅអតិថិជនទាំងនោះវិញក្នុងទម្រង់ដែលបានកំណត់ទុកមុន។

**២.២.២ ប្រវត្តិប្រាក់បញ្ញើ**

ប្រាក់បញ្ញើត្រូវបានបង្កើតឡើងដោយបទដ្ឋានបច្ចុប្បន្ន ដែលគ្រប់គ្រងសកម្មភាពមីក្រូហិរញ្ញវត្ថុប្រាក់បញ្ញើគឺជាលទ្ធផលមួយនៃការវិវត្តន៍ជាច្រើនសតវត្សនៃការបង្កើតគណនីមីក្រូហិរញ្ញវត្ថុ លក្ខណៈច្បាប់នៃគណនីមីក្រូហិរញ្ញវត្ថុ ប្រធានបទនៃការដាក់ប្រាក់បញ្ញើ និងស្ថាប័នមីក្រូហិរញ្ញវត្ថុខ្លួនឯង។ អរិយធម៌ និងវប្បធម៌ផ្សេងៗគ្នាបានរួមចំណែកដល់ការបង្កើតសកម្មភាពដាក់ប្រាក់ពីសម័យបុរាណ រហូតដល់មជ្ឈិមសម័យ យុគសម័យដើម ដល់សម័យទំនើប។ កិច្ចពិភាក្សាត្រូវបានកំណត់ប្រឆាំងនឹងផ្នែកហិរញ្ញវត្ថុ និងផ្នែកច្បាប់យ៉ាងទូលំទូលាយដើម្បីរួមបញ្ចូលការផ្លាស់ប្តូរអំណាចសេដ្ឋកិច្ចដែលអមជាមួយនឹងសកម្មភាពដាក់ប្រាក់ដែលបង្ហាញក្នុងទម្រង់ជាលុយទំនិញ ដុំមាស ប្រាក់ក្រដាស និងមូលនិធិ។ រូបភាពនៃការវិវត្តន៍ត្រូវបានបញ្ចប់ដោយស្ថាប័នដែលកំពុងរីកចម្រើននៃការត្រួតពិនិត្យ តម្រូវការដើមទុន ឬគ្រោងការណ៍ធានាប្រាក់បញ្ញើដែលបង្កើតបានជាដំណោះស្រាយបទដ្ឋានមួយចំនួនដែលត្រូវបានអនុម័ត ដោយសារតែតម្រូវការក្នុងការផ្តល់នូវក្របខ័ណ្ឌសម្រាប់សកម្មភាពដាក់ប្រាក់ ដែលនឹងផ្តល់អាទិភាពដល់សុវត្ថិភាពរបស់អ្នកដាក់ប្រាក់បញ្ញើ។ វាបម្រើដើម្បីប្រមូល និងបង្ហាញចំណេះដឹងផ្នែកច្បាប់ ប្រវត្តិសាស្ត្រ ដែលទទួលបានរួចហើយអំពីមូលដ្ឋានគ្រឹះនៃដំណោះស្រាយបទដ្ឋានសហសម័យនៃសកម្មភាពដាក់ប្រាក់បញ្ញើរបស់មីក្រូហិរញ្ញវត្ថុ។

**២.២.៣ ប្រភេទប្រាក់បញ្ញើ**

ប្រាក់បញ្ញើត្រូវបានគេបែងចែកជា៣ប្រភេទគឺៈ

- បញ្ញើតាមតម្រូវការ
- បញ្ញើសន្សំ
- បញ្ញើមានកាលកំណត់។
  - បញ្ញើតាមតម្រូវការ គឺជាគណនីដែលអនុញ្ញាតឱ្យអតិថិជន អាចដាក់សាច់ប្រាក់សន្សំដើម្បីសុវត្ថិភាពប៉ុន្តែមិនទទួលបានការប្រាក់នោះទេ ហើយអាចដកសាច់ប្រាក់មកវិញបានតាមតម្រូវការ។ នៅរាល់ប្រតិបត្តិការគណនីប្រចាំខែ នឹងបោះពុម្ពក្នុងទម្រង់ជា Bank Statement ហើយប្រគល់ជូនអតិថិជនដោយពុំយកកម្រៃសេវាឡើយ។
  - បញ្ញើសន្សំ គឺជាគណនីមួយប្រភេទ ដែលអនុញ្ញាតឱ្យអតិថិជនអាចដាក់សាច់ប្រាក់សន្សំដើម្បីសុវត្ថិភាព និងទទួលបានការប្រាក់ជារៀងរាល់ខែ ដោយស្វ័យប្រវត្តិ ហើយអាចដកសាច់ប្រាក់វិញបានតាមតម្រូវការ ដោយប្រើប្រាស់សៀវភៅប្រាក់បញ្ញើសម្រាប់កត់ត្រារាល់ប្រតិបត្តិការគណនី ឬប្រើប្រាស់ប័ណ្ណព័ត៌មានគណនី សម្រាប់បញ្ជាក់អត្តសញ្ញាណនៃគណនី។[4]
  - បញ្ញើមានកាលកំណត់ គឺជាប្រភេទគណនីដែលផ្តល់ជូនអត្រាការប្រាក់ខ្ពស់ សម្រាប់អតិថិជនដែលមានបំណងរក្សាទុកប្រាក់បញ្ញើក្នុងកាលបរិច្ឆេទដាក់លាក់ណាមួយ។

[4] SME Bank. (2022, November 4). គណនីបញ្ញើសន្សំ. Retrieved June 15 2025 from https://www.smebankcambodia.com.kh/km-kh/saving-account/

អតិថិជនមានជម្រើសក្នុងការទទួលយកអត្រាការប្រាក់បាននៅរៀងរាល់ចុងខែនីមួយៗ ឬនៅចុងការិយបរិច្ឆេទទៅតាមតម្រូវការ។

## ២.៣ នីតិវិធីក្នុងការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

### ២.៣.១ និយមន័យនីតិ

- **នីតិ ៖** ជាបណ្តុំវិធានគតិយុត្តទាំងឡាយដែលមានគោលដៅធ្វើឱ្យសង្គមមនុស្សមានសណ្តាប់ធ្នាប់ និងអមមកជាមួយដោយទណ្ឌកម្ម។[5]
- **នីតិ៖** គឺជាបណ្តុំវិធានគតិយុត្តដែលមានចំណងសិទ្ធិ និងកាតព្វកិច្ចមានអានុភាពចាប់បង្ខំមានលក្ខណៈទូទៅមិនចំពោះ និងមានគោលដៅរៀបចំសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយក្នុងសង្គម។ នីតិត្រូវបានបែងចែកជាពីរ គឺនីតិអន្តរជាតិ និងនីតិជាតិ។
- **នីតិ៖** គឺជាវិធានដែលគ្រប់គ្រងជីវភាពរស់នៅក្នុងសង្គមដោយមានការដាក់ទណ្ឌកម្មពីអំណាចសាធារណៈ។
- **នីតិ៖** គឺជាវិធានទាំងឡាយដែលបានបង្កើតឡើង សម្រាប់គ្រប់គ្រងជីវភាពរស់នៅរបស់មនុស្សក្នុងសង្គម ឱ្យមានសណ្តាប់ធ្នាប់ សន្តិសុខ សន្តិភាព សុខមាលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។[6]

### ២.៣.២ ប្រវត្តិនីតិ

នៅសម័យសង្គមបុព្វកាលមនុស្សរស់នៅដោយគ្មានច្បាប់អ្វីទាំងអស់ ប៉ុន្តែមនុស្សបែរជារៀបចំបែបផែនជាទំនៀមទម្លាប់ប្រពៃណី ឬជាបណ្តុំនៃវិធានគតិយុត្តដែលមានចំណងសិទ្ធិ និងកាតព្វកិច្ច លក្ខណៈទូទៅមិនចំពោះនិងមានគោលដៅរៀបចំសណ្តាប់ធ្នាប់សាធារណៈ ជាលំដាប់ ក្បួន បែប ពួក ប៉ែក ឬជាការប្រមូលផ្តុំចងក្រងនូវរាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលស្ថិតនៅក្នុងវិស័យតែមួយ ឬគ្រួសារតែមួយ។ ការសិក្សាអំពីការអភិវឌ្ឍ និងការវិវត្តនៃប្រព័ន្ធច្បាប់ រួមទាំងគោលគំនិតតាមពេលវេលាដែលជះឥទ្ធិពលដល់កត្តាសង្គម នយោបាយ សេដ្ឋកិច្ច និងវប្បធម៌ គំនិតច្បាប់ព្រមទាំងស្ថាប័ននានាបានលេចឡើង និងផ្លាស់ប្តូរនៅទូទាំងសម័យកាល និងអរិយធម៌ផ្សេងៗគ្នា។

នេះជាទិដ្ឋភាពលម្អិតបន្ថែមទៀតអំពីប្រវត្តិនៃនីតិ៖

ទិដ្ឋភាពសំខាន់ៗ និងរយៈពេល៖

- **ប្រព័ន្ធច្បាប់បុរាណ**
  - មេសូប៉ូតាមៀ៖ ក្រមនៃហាំមូរ៉ាប៊ី ដែលជាច្បាប់មួយពីបាប៊ីឡូនបុរាណ គឺជាក្រមច្បាប់ដែលគេស្គាល់ដំបូងបំផុតដែលមានអាយុកាលប្រហែលឆ្នាំ ១៧៥០ មុនគ.ស.។
  - ក្រិកបុរាណ៖ ជនជាតិក្រិចបុរាណបានបង្កើតគំនិតនៃលទ្ធិប្រជាធិបតេយ្យ និងយុត្តិធម៌ ដែលមានឥទ្ធិពលលើប្រព័ន្ធច្បាប់នៅពេលក្រោយ។

[5] Facebook page. Kanann Neam-Law. (Mar.13.2022). *នីតិ*. Retrieved June, 15 2025 from https://www.facebook.com/share/1AbtcvqwgP/

[6] Facebook page. Kanan Neam-Law. (Jun.27.2022) *នីតិ* Retrieved June, 15 2025 from https://www.facebook.com/share/p/16MTirjBRx/

- ទីក្រុងរ៉ូមបុរាណ៖ ច្បាប់រ៉ូម៉ាំង ជាពិសេស Corpus Juris Civilis (តួនៃច្បាប់ស៊ីវិល) ដែលចងក្រងដោយអធិរាជ Justinian មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់នៅអឺរ៉ុប និងលើសពីនេះ។

- **យុគសម័យមជ្ឈិមសម័យ**

- សក្តិភូមិ៖ ក្នុងសម័យសក្តិភូមិ ច្បាប់ជាញឹកញាប់ត្រូវបានធ្វើមូលដ្ឋានីយកម្ម និងផ្អែកលើទំនៀមទម្លាប់ និងប្រពៃណី។
- ច្បាប់ Canon៖ សាសនាចក្របានបង្កើតប្រព័ន្ធច្បាប់របស់ខ្លួន ដែលត្រូវបានគេស្គាល់ថាជាច្បាប់ Canon ដែលទាក់ទងនឹងបញ្ហាសាសនា។
- ការកើនឡើងនៃជាតិ-រដ្ឋ៖ ការកើនឡើងនៃរដ្ឋជាតិនាំទៅដល់ការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ដែលបានធ្វើកូដកម្ម ដូចជា ក្រមណាប៉ូឡេអុងបារាំង។
- ច្បាប់ទូទៅ៖ ប្រពៃណីច្បាប់ទូទៅដែលបានបង្កើតឡើងនៅក្នុងប្រទេសអង់គ្លេសគឺផ្អែកលើច្បាប់មុនគេជាជាងច្បាប់ដែលបានធ្វើកូដ។
- ឥទ្ធិពលនៃទស្សនវិទូផ្នែកច្បាប់៖ អ្នកគិតដូចជា John Locke និង Montesquieu បាន ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការគិតផ្នែកច្បាប់ និងការអភិវឌ្ឍន៍នៃរដ្ឋធម្មនុញ្ញនិយម។

- **ប្រព័ន្ធច្បាប់ទំនើប**
- ច្បាប់រដ្ឋប្បវេណី៖ ប្រព័ន្ធច្បាប់ស៊ីវិល ដែលផ្អែកលើច្បាប់ដែលបានធ្វើកូដកម្ម។

**២.៣.៣ មុខងារនីតិ**

នីតិត្រូវបានគេកំណត់មុខងារឡើងដើម្បី ទទួលបាននូវយុត្តិធម៌សមស្របទៅតាមច្បាប់ ក្នុងការកម្ចីប្រាក់របស់អតិថិជន។ លើសពីនេះ នីតិត្រូវបានគេកំណត់នៅពេលមានការកម្ចីពីអតិថិជន ដោយនីតិបានដាក់គោលដៅឱ្យអតិថិជនត្រូវទូទាត់សាច់ប្រាក់តាមពេលវេលាកំណត់ ប៉ុន្តែមុននឹងទទួលបានរាល់កម្ចីគឺតម្រូវឱ្យកូនបំណុលមានសំណើរឯកសារសំខាន់ៗ និងអ្នកធានា វាជានីតិដែលជួយសម្រួលក្នុងការអនុវត្តច្បាប់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

# ជំពូកទី៣

# នីតិវិធីក្នុងការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

## ៣.១ ស្ថានភាពទូទៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

### ៣.១.១ ប្រវត្តិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត




អម្រឹត មានដើមកំណើតមកពីគំនិតផ្តួចផ្តើមឥណទានជនបទតាំងពីឆ្នាំ១៩៩១ ដោយអង្គការបារាំងមួយ ហៅថាហ្គ្រេត( GRET- Recherche et d'Echanges Technologiques ) ដែលមានតែ ៣ ខេត្តប៉ុណ្ណោះ។ ទស្សនវិស័យរបស់ហ្គ្រេត( GRET )គឺត្រូវមាននិរន្តរភាពយូរអង្វែង ដើម្បីគាំទ្រដល់សហគ្រិន ដោយផ្តល់ជូននូវឥណទានដែលមានការទទួលខុសត្រូវ និងអាចទទួលយកបានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត។ អម្រឹតដំបូងឡើយត្រូវបានគេទទួលស្គាល់ថាជាអ៊ីអឹមតេ ហើយវាជាប្រភេទគ្រឹះស្ថានដែលឈានមុខគេដែលមានបទពិសោធន៍ជាង២០ឆ្នាំមកហើយ។ដោយមានការគាំទ្រពីសំណាក់ស្ថាប័នជាតិ នឹង ស្ថាប័នអន្តរជាតិក៏ដូចជាអតិថិជនរបស់ខ្លួន អម្រឹតក៏បានប្រែក្លាយជាមីក្រូហិរញ្ញវត្ថុដំបូងគេដែលទទួលបានអាជ្ញាប័ណ្ណជាផ្លូវការពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ជាប្រភេទស្ថាប័នមួយដែលផ្តល់ជាសេវាកម្មជាច្រើន

ដល់ប្រជាពលរដ្ឋ ក្នុងប្រទេសកម្ពុជា ហើយសេវាកម្មទាំងនោះមានដូចជា ការផ្តល់ឥណទាន ដើម្បីវិនិយោគជាលក្ខណៈខ្នាតតូច មធ្យម ឬក៏ធំ ជាមួយនឹងអត្រាការប្រាក់សមរម្យ ប្រាក់បញ្ញើសន្សំជាដើម។ ឆ្នាំ១៩៩១ អង្គការនេះ បានធ្វើសកម្មភាពក្នុងការផ្តល់ប្រាក់កម្ចីជូនប្រជាពលរដ្ឋ ដោយមានការសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺក្រោយពីពេល ហ្រ្គេត (GRET) បានប្រារព្ធធ្វើសិក្ខាសាលាមួយនៅខែឧសភា ឆ្នាំ១៩៩១ ដោយពេលនោះមានសិក្ខាកាមចូលរួមចំនួនប្រមាណតែ ៥០នាក់តែប៉ុណ្ណោះ។ សិក្ខាសាលានៅពេលនោះគឺបានសម្រេច និងធ្វើការប្តេជ្ញាដោយផ្តោតសំខាន់ និងកំណត់គោលដៅតែមួយគត់ គឺការផ្តល់ឥណទានជូនប្រជាពលរដ្ឋ ដែលការផ្តល់ឥណទាន នោះគឺត្រូវតែមានចីរភាព និងនិរន្តរភាពយូរអង្វែង។ ការផ្តល់ឥណទានរបស់ ហ្រ្គេត (GRET) គឺត្រូវតែមានភាពងាយស្រួល និងជួយបង្កើនស្ថានភាពរស់នៅរបស់អ្នកខ្ចីឲ្យបានប្រសើរឡើង។ នីតិវិធីក្នុងការផ្តល់ឥណទានរបស់ ហ្រ្គេត(GRET) ត្រូវបាន អនុវត្តតាមការផ្តល់ឥណទានតាមធនាគារ Grameen Bank គឺបង្កើតក្រុមសាមគ្គីដោយធានាគ្នាដើម្បីខ្ចីប្រាក់។

អម្រឹត ពីដំបូងឡើយគឺត្រូវបានគេស្គាល់ និងចាំថាជា ឥណទានមូលដ្ឋានជនបទ (Ennetean Moulethan Tchonnebath) ដែលឈ្មោះនេះហៅជាអក្សរកាត់ថា អី អឹម តេ (EMT) តែដោយសារឈ្មោះនេះគឺមានលក្ខណៈវែង និងមួយវិញទៀត យើងបានហៅឈ្មោះនេះតែជាអក្សរកាត់គឺ អី អឹម តេ (EMT) តែប៉ុណ្ណោះ គឺមិនបានហៅឈ្មោះពេញថា ឥណទានមូលដ្ឋានជនបទ (Ennetean MoulethanTchonnebath) នោះទេ។

ការហៅឈ្មោះ អី អឹម តេ នោះទៀតសោត គឺភាគច្រើនហៅឈ្មោះមិនបានត្រឹមត្រូវទៀត ព្រោះមនុស្សភាគច្រើននៅកម្ពុជានាសម័យបច្ចុប្បន្នគឺចូលចិត្តប្រើភាសាអង់គ្លេសច្រើន ដូច្នេះអ្នកទាំងនោះគឺតែងតែហៅឈ្មោះ អី អឹម តេ ថា អ៊ី អឹម ធី ទៅវិញ ហើយអ្វីដែលចម្លែកជាងនេះទៅទៀតនោះ គឺអតិថិជនភាគច្រើនរបស់ ស្ថាប័នដែលរស់នៅឯជនបទតែងតែហៅឈ្មោះស្ថាប័នមិនបានត្រឹមត្រូវ និងពេញលេញនោះទេ គឺបានហៅឈ្មោះដោយបាត់អក្សរ និងពាក្យមួយចំនួន ដូចជា អ្នកខ្លះហៅថា អឹម តេ អ្នកខ្លះហៅថា អី តេ អ្នកខ្លះហៅថា តេ តេ អាស្រ័យហេតុនេះហើយទើបគណៈគ្រប់គ្រងរបស់ស្ថាប័នបានសម្រេចធ្វើការផ្លាស់ប្តូរឈ្មោះដោយធ្វើការសិក្សា ពិនិត្យយ៉ាងល្អិតល្អន់ និងត្រឹមត្រូវ ដោយមានបណ្ឌិតផ្នែកអក្សរសាស្រ្តខ្មែរផ្តល់ជាយោបល់ និងពន្យល់ពីអត្ថន័យនៃពាក្យ អម្រឹត ដោយមានការសិក្សាពីអត្ថន័យ សូរសព្ទ និងសូរសៀង នៃឈ្មោះ អម្រឹត ជាមួយអតិថិជនរបស់ខ្លួន និងពិសេសជាមួយជនជាតិមួយចំនួន ដែលរស់នៅលើទឹកដីខ្មែរ មានដូចជាជនជាតិចាម ជនជាតិវៀតណាម និងជនជាតិផ្សេងៗទៀតហើយឈ្មោះនេះ គឺបងប្អូនជនជាតិទាំងនោះបានប្រាប់ថាមាន អត្ថន័យល្អមិនមានន័យអាក្រក់ចំពោះភាសារបស់គេឡើយ និងមួយវិញទៀតគឺ មិនមានពាក្យគន្លាស់កាត់ជាពាក្យអាក្រក់ឡើយ។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

#### ❖ ចក្ខុវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខ ដែលរួមចំណែកក្នុងការកែលម្អជីវភាពប្រជាពលរដ្ឋឲ្យល្អប្រសើរ រួមទាំងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា។

❖ បេសកកម្ម និង គោលដៅ

ផ្តល់សេវាហិរញ្ញវត្ថុច្រើនប្រភេទដល់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប និងសហគ្រាសខ្នាតតូចបំផុតនិងមធ្យម ដោយធានាបាននូវលទ្ធផលប្រតិបត្តិការកម្រិតខ្ពស់ផ្នែកហិរញ្ញវត្ថុ និងសង្គម។

## ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត




❖ **នាទី និងភារកិច្ច របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់កម្ចី ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់សេវាសុខភាព សេវាធានារ៉ាប់រង និងសេវាកម្មផ្សេងៗទៀត។ អ្នកផ្តល់កម្ចីដល់កសិករទាំងឡាយ សម្រាប់ទិញឧបករណ៍និងមធ្យោបាយកសិកម្ម។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីចម្បងដូចខាងក្រោម៖

- តួនាទីអន្តរការី( The Intermediation role ) ៖ តួនាទីនេះអនុវត្តការផ្ទេរប្រាក់សន្សំពីបណ្តាគ្រួសារ និងបង្វែរពួកវាទៅជាការផ្តល់ឥណទានឲ្យទៅបណ្តាគ្រួសារ និងបុគ្គល ដើម្បីធ្វើការវិនិយោគជាមួយនឹងគោលដៅបង្កើតប្រាក់ចំណេញ ឬលើកកម្ពស់ជីវភាពរស់នៅ។
- តួនាទីជាអ្នកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវអនុវត្តតាមគោលនយោបាយរូបិយវត្ថុ និងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ដោយចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិជាពិសេស ការអភិវឌ្ឍសេដ្ឋកិច្ចជនបទឲ្យបានរីកចម្រើន និងបង្កើនស្តង់ដារនៃការរស់នៅរបស់ពលរដ្ឋនៅក្នុងសង្គម។

- តួនាទីអភិវឌ្ឍន៍ជនបទ(Role of Rural Development) ៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់ដើម្បីជួយកាត់បន្ថយភាពក្រីក្រនិងបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់កម្ចី ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់សេវាសុខភាព សេវាធានារ៉ាប់រង និងសេវាកម្មផ្សេងៗទៀត។

## ៣.២ សេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

### ៣.២.១ ប្រាក់បញ្ញើសន្សំ

វិនិយោគសាច់ប្រាក់របស់លោកអ្នកជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ជាប្រភពចំណូលបន្ថែម។ ប្រាក់របស់លោកអ្នកមានកំណើនជារៀងរាល់ថ្ងៃ ធ្វើឱ្យលោកអ្នកសម្រេចក្តីប្រាថ្នានិងធានាបាននូវសុវត្ថិភាពខ្ពស់។ លោកអ្នកអាចជ្រើសរើសប្រភេទគណនីសន្សំប្រាក់នៅអម្រឹត បានតាមតម្រូវការ។ រួមមានដូចជា :

- គណនីបញ្ញើមានកាលកំណត់
- គណនីក្មេងឆ្លាត
- គណនីប្រាថ្នា
- គណនីបញ្ញើ Flexi
- គណនីចម្រើន។

### ៣.២.២ ប្រាក់បញ្ញើមានកាលកំណត់

#### ក.គណនីមានកាលកំណត់

វិនិយោគចំនួនទឹកប្រាក់ណាមួយដែលអ្នកមានជាមួយនឹងគណនីមានកាលកំណត់នៅ អម្រឹត ដោយធានានូវសុវត្ថិភាព និងទទួលបានអត្រាការប្រាក់ហូតដល់ទៅ ៧,៤៥%។ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ម្ចាស់ភាគហ៊ុនអន្តរជាតិ និងកេរ្តិ៍ឈ្មោះរបស់អម្រឹតគឺជាជម្រើសសម្រាប់សាច់ប្រាក់របស់អ្នក។




• ទទួលបានឥណទានគ្មានទ្រព្យបញ្ចាំ អាចស្នើឥណទានគ្មានទ្រព្យបញ្ចាំពី អម្រឹតដោយគ្រាន់តែបង្ហាញប័ណ្ណសន្សំប្រាក់

• អាចដកប្រាក់សន្សំនៅពេលចាំបាច់ទទួលបានការប្រាក់ បើទោះជាលោកអ្នកដកប្រាក់សន្សំមុនកាលកំណត់។

## លក្ខណៈពិសេស

> ចាប់ផ្តើមសន្សំដោយទាបបំផុតត្រឹម ៥០ ដុល្លារ

> អត្រាការប្រាក់រហូតដល់ ៧,៤៥%

> ជ្រើសរើសការដកការប្រាក់ប្រចាំខែ ឬ ការដកការប្រាក់នៅកាលកំណត់។

## អត្ថប្រយោជន៍

>ទទួលបានកម្ចីពីអម្រឹត ដោយមិនទាមទារទ្រព្យបញ្ចាំ

> អាចដាក់ពាក្យស្នើសុំឥណទានពិសេសពី អម្រឹត

> ធ្វើការសន្សំជាមួយនឹងអម្រឹត អ្នកនឹងចូលរួមចំណែកក្នុងការគាំទ្រការអភិវឌ្ឍប្រទេសកម្ពុជា

> អ្នកអាចដកប្រាក់សន្សំមុនកាលកំណត់បាននៅពេលដែលអ្នកត្រូវការ ហើយអ្នកនឹងនៅតែទទួលបានអត្រាការប្រាក់។

## តាមរយៈអម្រឹតMobile

| លក្ខខណ្ឌ | ចំនួនប្រាក់បញ្ញើប្រចាំខែ | | អត្រាការប្រាក់ប្រចាំឆ្នាំ | | | |
|---|---|---|---|---|---|---|
| | | | ដកប្រាក់នៅកាលកំណត់ | | ដកប្រាក់ប្រចាំខែ | |
| | រៀល | ដុល្លារ | រៀល | ដុល្លារ | រៀល | ដុល្លារ |
| ១ ខែ | ២០០.០០០ | ៥០ | ២,៦០% | ២,៦០% | គ្មាន | គ្មាន |
| ៣ ខែ | | | ៣,១០% | ៣,១០% | ២,៦០% | ២,៦០% |
| ៦ ខែ | | | ៤,៥០% | ៤,៥០% | ៤,០០% | ៤,០០% |
| ៩ ខែ | | | ៥,០០% | ៥,០០% | ៤,៥០% | ៤,៥០% |
| ១២ ខែ | | | ៥,៥០% | ៥,៥០% | ៥,០០% | ៥,០០% |
| ១៨ ខែ | | | ៦,០០% | ៦,០០% | ៥,៥០% | ៥,៥០% |
| ២៤ ខែ | | | ៦,២៥% | ៦,២៥% | ៥,៧៥% | ៥,៧៥% |
| ៣០ ខែ | | | ៧,១៥% | ៧,១៥% | ៦,៦៥% | ៦,៦៥% |
| ៣៦ ខែ | | | ៧,១៥% | ៧,១៥% | ៦,៦៥% | ៦,៦៥% |
| ៤៨ ខែ | | | ៧,៣៥% | ៧,៣៥% | ៦,៨៥% | ៦,៨៥% |
| ៦០ ខែ | | | ៧,៤៥% | ៧,៤៥% | ៦,៩៥% | ៦,៩៥% |

### ខ. គណនីក្មេងឆ្លាត

ម្ដាយនិងបុត្រធីតា ដោយផ្ដល់ជូនភាពបត់បែនខ្ពស់សម្រាប់មាតាបិតា ក្នុងការកំណត់គោលដៅសន្សំ និងចំនួនទឹកប្រាក់ត្រូវបង់ប្រចាំខែ ស្របតាមតម្រូវការផ្ទាល់ខ្លួន និងលទ្ធភាពជាក់ស្ដែងផ្នែកសម្រេចក្ដីស្រមៃនៃការសិក្សារបស់បុត្រធីតាលោកអ្នក ដោយផ្ដល់ជូននូវសុវត្ថិភាពផ្នែកហិរញ្ញវត្ថុសម្រាប់ពួកគេ។ ចាប់ផ្ដើមសន្សំសម្រាប់អនាគតរបស់ពួកគេនៅថ្ងៃនេះ ជាមួយនឹងគណនីក្មេងឆ្លាតជាមួយនឹងផែនការសន្សំប្រចាំខែត្រឹមតែ ១០ដុល្លារ។

គណនីក្មេងឆ្លាតជាគណនីសន្សំរួមគ្នារវាងឪពុកហិរញ្ញវត្ថុ។ លើសពីនេះទៅទៀត ម្ចាស់គណនីនឹងត្រូវបានការពារដោយកញ្ចប់ធានារ៉ាប់រងអាយុជីវិតឥតគិតថ្លៃ ក្នុងទឹកប្រាក់ ៤.០០០ ដុល្លារក្នុងអំឡុងពេលសន្សំប្រាក់នេះ ព្រមទាំងទទួលបានប្រាក់រង្វាន់លើកទឹកចិត្តជាសាច់ប្រាក់ហូតដល់១.០០០ ដុល្លារសម្រាប់បុត្រធីតានៅពេលបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ។




• សន្សំមានភាពបត់បែន ស្របតាមលទ្ធភាព របស់អតិថិជន សន្សំត្រឹមតែ ១.៥០០រៀលក្នុង១ថ្ងៃសម្រាប់បន្តការសិក្សាមហាវិទ្យាល័យ

• ទទួលបានឥតគិតថ្លៃ ធានារ៉ាប់រងអាយុជីវិត ៤.០០០ ដុល្លារ ដោយឥតគិតថ្លៃក្នុងអំឡុងពេលសន្សំប្រាក់

• ផ្ដល់ជូនប្រាក់លើកទឹកចិត្តបន្ថែម រហូតដល់ ១.០០០ដុល្លារ ក្រោយបញ្ចប់ការសិក្សាថ្នាក់ទី១២។

**លក្ខខណ្ឌតម្រូវ**

> ឪពុកម្ដាយ ឬ អាណាព្យាបាល( និវាសជន ឬ អនិវាសជន ) ត្រូវមានអាយុចាប់ពី អាយុ១៨ ឆ្នាំឡើង

> កុមារ៖ មានអាយុចាប់ពី ១ខែឡើង និង/ឬ កំពុងសិក្សាក្រោមថ្នាក់ទី១០។

**អត្ថប្រយោជន៍**

> សន្សំត្រឹមតែ ១.៥០០ រៀលក្នុងមួយថ្ងៃសម្រាប់បន្តការសិក្សាមហាវិទ្យាល័យ

> ទទួលបានកញ្ចប់ធានារ៉ាប់រងអាយុជីវិត ៤.០០០ ដុល្លារ ដោយឥតគិតថ្លៃ

> ផ្ដល់ជូនលើកទឹកចិត្តបន្ថែមរហូតដល់ ១.០០០ ដុល្លារ

## ព័ត៌មានលម្អិត

| ផែនការប្រាក់ត្រូវសន្សំ | កញ្ចប់ $2,000 | កញ្ចប់ $3,000 | កញ្ចប់ $4,000 | កញ្ចប់ $5,000 | កញ្ចប់ $6,000 | កញ្ចប់ $7,000 | កញ្ចប់ $8,000 | កញ្ចប់ $9,000 | កញ្ចប់ $10,000 | កញ្ចប់ $15,000 | កញ្ចប់ $20,000 |
|---|---|---|---|---|---|---|---|---|---|---|---|
| អាយុ/ថ្នាក់ របស់កុមារ | ចំនួនទឹកប្រាក់ត្រូវសន្សំប្រចាំខែ(ចំនួនប្រហាក់ប្រហែល) | | | | | | | | | | |
| កូនអាយុ 1ខែ-1ឆ្នាំ | $10 | $12 | $16 | $20 | $24 | $28 | $32 | $36 | $40 | $60 | $79 |
| កូនអាយុ 1ឆ្នាំ-2ឆ្នាំ | $8-9 | $12-13 | $16-17 | $20-22 | $24--26 | $28-30 | $32-34 | $36-39 | $40-43 | $60-64 | $79-85 |
| កូនអាយុ 2ឆ្នាំ- 3ឆ្នាំ | $9-10 | $13-14 | $17-19 | $22-23 | $26-28 | $30-32 | $34-37 | $39-42 | $43-46 | $64-69 | $85-92 |
| កូនអាយុ 3ឆ្នាំ- 4ឆ្នាំ | $10 | $14-15 | $19-20 | $23-25 | $28-30 | $32-35 | $37-40 | $42-45 | $46-50 | $69-75 | $92-99 |
| កូនអាយុ 4ឆ្នាំ- 5ឆ្នាំ | $11-12 | $15-17 | $20-22 | $25-27 | $30-33 | $35-38 | $40-44 | $45-49 | $50-54 | $75-81 | $99-108 |
| កូនអាយុ 5ឆ្នាំ- 6ឆ្នាំ | $11-12 | $17-18 | $22-24 | $27-30 | $33-36 | $38-42 | $44-48 | $49-54 | $54-60 | $81-89 | $108-119 |
| កូនកំពុងរៀនថ្នាក់ទី1 | $12-14 | $18-20 | $24-27 | $30-33 | $36-40 | $42-46 | $48-53 | $54-59 | $60-66 | $89-98 | $119-131 |
| កូនកំពុងរៀនថ្នាក់ទី2 ឬ បានបញ្ចប់ថ្នាក់ទី1 | $14-15 | $20-22 | $27-30 | $33-37 | $40-44 | $46-51 | $53-59 | $59-66 | $66-73 | $98-110 | $131-146 |
| កូនកំពុងរៀនថ្នាក់ទី3 ឬ បានបញ្ចប់ថ្នាក់ទី2 | $15-17 | $22-25 | $30-33 | $37-41 | $44-50 | $51-58 | $59-66 | $66-74 | $73-82 | $110-123 | $146-164 |
| កូនកំពុងរៀនថ្នាក់ទី4 ឬ បានបញ្ចប់ថ្នាក់ទី3 | $17-19 | $25-28 | $33-38 | $41-47 | $50-56 | $58-66 | $66-75 | $74-84 | $82-94 | $123-140 | $164-187 |
| កូនកំពុងរៀនថ្នាក់ទី5 ឬ បានបញ្ចប់ថ្នាក់ទី4 | $22-26 | $28-33 | $38-44 | $47-55 | $56-65 | $66-76 | $75-87 | $84-98 | $94-109 | $140-163 | $187-217 |
| កូនកំពុងរៀនថ្នាក់ទី6 ឬ បានបញ្ចប់ថ្នាក់ទី5 | $22-26 | $33-39 | $44-52 | $55-64 | $65-77 | $76-90 | $87-103 | $98-115 | $109-128 | $163-192 | $217-256 |
| កូនកំពុងរៀនថ្នាក់ទី7 ឬ បានបញ្ចប់ថ្នាក់ទី6 | $26-32 | $39-47 | $52-63 | $64-78 | $77-94 | $90-109 | $103-125 | $115-140 | $128-156 | $192-233 | $256-311 |
| កូនកំពុងរៀនថ្នាក់ទី8 ឬ បានបញ្ចប់ថ្នាក់ទី7 | $32-40 | $47-60 | $63-79 | $78-99 | $94-119 | $109-138 | $125-158 | $140-178 | $156-197 | $233-296 | $311-394 |
| កូនកំពុងរៀនថ្នាក់ទី9 ឬ បានបញ្ចប់ ថ្នាក់ទី8 | $40-54 | $60-80 | $79-107 | $99-133 | $119-160 | $138-187 | $158-213 | $178-240 | $197-266 | $296-399 | $394-532 |

**គ.គណនីប្រាថ្នា**

អ្នកចង់ទិញម៉ូតូ ចង់សន្សំសម្រាប់ថ្លៃសាលារបស់កូនអ្នក ឬ សម្រាប់ពេលចូលនិវត្តន៍? អ្នកចង់មានប្រាក់គ្រប់គ្រាន់ក្នុងករណីមានតម្រូវការចាំបាច់បន្ទាន់ ឬករណីចាំបាច់កើតឡើងដោយមិនបានរំពឹងទុក? ចាប់ផ្តើមប្រើប្រាស់គណនីសម្រេចប្រាថ្នារបស់ អម្រឹត ទោះបីជាមានចំនួនតិចតួចក៏ដោយ ដាក់ចំនួនទឹកប្រាក់ដែលជាជម្រើសរបស់អ្នកឲ្យបានទៀងទាត់ ដើម្បីទទួលបានអត្រាការប្រាក់ខ្ពស់រហូតឈានដល់គោលដៅរបស់អ្នក។




- អត្រាការប្រាក់ខ្ពស់ទទួលបានអត្រាការប្រាក់រហូតដល់ ៧,២៥%ក្នុងមួយឆ្នាំ
- គម្រោងសន្សំបត់បែនខ្ពស់ចាប់ផ្ដើមសន្សំចាប់ពី ៥ដុល្លារក្នុងមួយខែ
- អាចដកប្រាក់សន្សំនៅពេលចាំបាច់ ទទួលបានការប្រាក់សមស្របទោះបីអ្នកដកប្រាក់សន្សំមុនកាលកំណត់។

**លក្ខណៈពិសេស**

> ចាប់ផ្ដើមសន្សំចាប់ពី ៥ ដុល្លារក្នុងមួយខែ

> ជ្រើសរើសប្រភេទរូបិយប័ណ្ណ ប្រាក់រៀល ដុល្លារ និងរយៈពេលនៃការសន្សំ

> សន្សំកាន់តែយូរ អ្នកនឹងទទួលបានអត្រាការប្រាក់កាន់តែខ្ពស់រហូតដល់ ៧.២៥%។

**អត្ថប្រយោជន៍**

> អ្នកអាចដកប្រាក់សន្សំមុនកាលកំណត់បាននៅពេលដែលអ្នកត្រូវការ ហើយអ្នកនឹងនៅតែទទួលបានអត្រាការប្រាក់។

**ព័ត៌មានលម្អិត**

| លក្ខខណ្ឌ | ចំនួនប្រាក់បញ្ញើប្រចាំខែ | | អត្រាការប្រាក់ប្រចាំឆ្នាំ | |
|---|---|---|---|---|
| | រៀល | ដុល្លារ | រៀល | ដុល្លារ |
| ៦ ខែ | ២០.០០០ | ៥ | ៥,00% | ៥,00% |
| ១២ ខែ | | | ៥,៥0% | ៥,៥0% |
| ២៤ ខែ | | | ៦,00% | ៦,00% |
| ៣៦ ខែ | | | ៦,៥0% | ៦,៥0% |
| ៤៨ ខែ | | | ៧,00% | ៧,00% |
| ៦០ ខែ | | | ៧,២៥% | ៧,២៥% |

**ឃ.គណនី** Flexi

វិនិយោគចំនួនទឹកប្រាក់ណាមួយដែលអ្នកមានជាមួយនឹងគណនីបញ្ញើសន្សំ Flexi នៅអម្រឹត ដោយធានានូវសុវត្ថិភាព និងទទួលបានអត្រាការប្រាក់រហូតដល់ទៅ ៥.៦៥%។ រីករាយជាមួយភាពបត់បែននៃការដកប្រាក់ ដោយមិនបាត់បង់អត្រាការប្រាក់នៃចំនួនដែលនៅសល់។




- អត្រាការប្រាក់ខ្ពស់ ទទួលបានអត្រាការប្រាក់រហូតដល់ ៥.៦៥% ក្នុងមួយឆ្នាំ
- គម្រោងសន្សំបត់បែនខ្ពស់ ចាប់ផ្ដើមសន្សំចាប់ពី ១.០០០ដុល្លារ ក្នុងមួយខែ
- អាចដកប្រាក់សន្សំនៅពេលចាំបាច់ ទទួលបានការប្រាក់ បើទោះជាលោកអ្នកដកប្រាក់សន្សំមុនកាលកំណត់។

### អត្ថប្រយោជន៍

អ្នកអាចដកប្រាក់សន្សំមុនកាលកំណត់បាននៅពេលដែលអ្នកត្រូវការហើយអ្នកនឹងនៅតែទទួលបាន អត្រាការប្រាក់។

### លក្ខណៈពិសេស

> ចាប់ផ្តើមសន្សំចាប់ពី ១,០០០ ដុល្លារ

> អត្រាការប្រាក់រហូតដល់ ៥.៦៥%

> សម្រាប់អត្រាការប្រាក់ទទួលបាននៅកាលកំណត់។

| លក្ខខណ្ឌ | ចំនួនប្រាក់បញ្ញើប្រចាំខែ | | អត្រាការប្រាក់ប្រចាំឆ្នាំ ដកប្រាក់ប្រចាំខែ | |
|---|---|---|---|---|
| | រៀល | ដុល្លារ | រៀល | ដុល្លារ |
| ១២ ខែ | ៤,000,000 | ១,000 | ៤,00% | ៤,00% |
| ១៨ ខែ | | | ៤,៥0% | ៤,៥0% |
| ២៤ ខែ | | | ៤,៧៥% | ៤,៧៥% |
| ៣៦ ខែ | | | ៥,៦៥% | ៥.៦៥% |

### ខ.គណនីចម្រើន

ជាប្រភេទគណនីសន្សំសម្រាប់តែអតិថិជនជារូបវន្តបុគ្គលដែលបំពេញតម្រូវការអតិថិជនមាន បំណងសន្សំដើម្បីទទួលបានការប្រាក់ខ្ពស់ និងធ្វើប្រតិបត្តិការហិរញ្ញវត្ថុសំខាន់ៗប្រចាំខែ។




### លក្ខណៈពិសេស

សមតុល្យអប្បបរមាពេលបើក និងតម្កល់ក្នុងគណនីក្រោយបើក ២០០

- អត្រាការប្រាក់រហូតដល់ ៤,២៥%

- រូបិយប័ណ្ណ៖ ដុល្លារ ឬ រៀល
- ចំនួនប្រតិបត្តិការដកប្រាក់៖

  * ≤ ៤ដង/ខែ ៖ ឥតគិតថ្លៃសេវា

  * > ៤ដង/ខែ ៖ ៣ដុល្លារ ឬ១២.០០០រៀល/ប្រតិបត្តិការ។

**អត្ថប្រយោជន៍**

អាចបង្កើតគណនី និងធ្វើប្រតិបត្តិការតាមរយៈអម្រឹតម៉ូបាល

> ការដាក់ប្រាក់មិនកំណត់ចំនួនប្រតិបត្តិការ

> មិនកំណត់ចំនួនទឹកប្រាក់ដែលដាក់ចូលគណនី។

**ឯកសារតម្រូវ**

លោកអ្នកអាចបើកគណនីបានដោយខ្លួនឯងភ្លាមៗតាមរយៈអម្រឹត ម៉ូបាល ឬនៅសាខាអម្រឹតណាមួយដែលនៅជិតលោកអ្នក។ សូមភ្ជាប់ឯកសារតម្រូវដូចខាងក្រោមសម្រាប់ការបើកគណនីជាមួយសាខារបស់យើង៖

១. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(នៅមានសុពលភាព)

២. លិខិតឆ្លងដែន(នៅមានសុពលភាព)

៣. សៀវភៅគ្រួសារ (បានតែមេគ្រួសារមានបិទរូបថត)។

### ៣.២.២.សេវាកម្មសន្សំចល័ត

អ្នកមានហាង ឬអាជីវកម្មមួយនៅលើទីផ្សារ ហើយចង់រក្សាប្រាក់ខ្លះនៅកន្លែងដែលមានសុវត្ថិភាព អ្នកមិនចាំបាច់ធ្វើដំណើរមកកាន់សាខារបស់ អម្រឹត នោះទេ។ មន្ត្រីសន្សំចល័តរបស់ អម្រឹត នឹងទៅទទួលយកប្រាក់សន្សំរបស់អ្នក មិនថានៅគេហដ្ឋាន ឬ នៅហាងរបស់អ្នកឡើយ។ អ្នកនឹងទទួលបានសារបញ្ជាក់នូវការដាក់សាច់ប្រាក់ ហើយបុគ្គលិកយើងនឹងធ្វើការកត់ត្រាប្រតិបត្តិការក្នុងកម្មវិធីទូរស័ព្ទដៃនៅចំពោះមុខអ្នកផ្ទាល់ ដែលមានសុវត្ថិភាព១០០%។

**អត្ថប្រយោជន៍**

> អ្នកអាចធ្វើការស្នើសុំឥណទានរហ័ស ហើយអ្នកនឹងទទួលបានក្នុងរយៈពេល ២៤ម៉ោងដោយមិនបាច់បញ្ចាំ

> អ្នកអាចធ្វើការដកប្រាក់ជាមួយនឹងបុគ្គលិករបស់យើង

> នៅពេលអ្នកធ្វើការសន្សំ អ្នកអាចបើកគណនីប្រាថ្នា ឬ គណនីមានកាលកំណត់

> អ្នកអាចធ្វើការស្នើសុំឥណទានបុគ្គល ឬ ឥណទានសម្រាប់អាជីវកម្ម

> សុវត្ថិភាពខ្ពស់សម្រាប់ប្រាក់សន្សំដែលអាចដកបានគ្រប់ពេលសម្រាប់ក្រុមគ្រួសារ ឬ អាជីវកម្មបន្ទាន់។

## ៣.៣ ហានិភ័យប្រឈមនៃសេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុទាំងឡាយ ប្រឈមនឹងហានិភ័យសំខាន់ៗដូចខាងក្រោម ៖

- ហានិភ័យហិរញ្ញវត្ថុ(Financial Risks)
- ហានិភ័យប្រតិបត្តិការ( Operational Risk)

- ➢ ហានិភ័យធុរកិច្ច( Business Risk )
- ➢ ហានិភ័យព្រឹត្តិការណ៍( Event Risk )។

**១. ហានិភ័យហិរញ្ញវត្ថុ**( Financial Risks )

**ក. ហានិភ័យឥណទាន( Credit Risk )**

– ហានិភ័យឥណទាន គឺជាឱកាសដែលកូនបំណុល ឬអ្នកប្រើប្រាស់ ឧបករណ៍ហិរញ្ញវត្ថុ មិនអាចមានលទ្ធភាពសងការប្រាក់ ឬសងប្រាក់ដើម តាមពេលវេលាជាក់លាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាផ្តល់ឥណទាន។

– ហានិភ័យឥណទាន មានន័យថា ការទូទាត់ត្រូវបានគេពន្យាពេល ឬមិនត្រូវបានគេសងទាំងស្រុង ដែលបណ្តាលឱ្យមានបញ្ហាដល់ចលនាសាច់ប្រាក់និងប៉ះពាល់ដល់សន្ទនីយភាពរបស់ស្ថាប័នហិរញ្ញវត្ថុមួយ។

**ខ. ហានិភ័យអត្រាការប្រាក់( Interest Rate Risk )**

- ការប្រែប្រួលអត្រាការប្រាក់ អាចមានឥទ្ធិពលទៅលើកំរិតប្រាក់ចំណូល ធៀបនឹងចំណាយប្រតិបត្តិការរបស់ស្ថាប័នហិរញ្ញវត្ថុ។

- ប្រសិនបើការចំណាយលើប្រាក់បញ្ញើ និងប្រាក់បានខ្ចីកើនឡើងលឿនជាងចំណូលការប្រាក់លើឥណទាន និងការវិនិយោគលើមូលបត្រ នោះអត្រាការប្រាក់របស់ស្ថាប័នក៏កើនឡើងផងដែរ និងកំរិតប្រាក់ចំណេញអាចមានការធ្លាក់ចុះ។

- ប្រសិនបើស្ថាប័នហិរញ្ញវត្ថុមានបរិមាណឲ្យខ្ចីក្នុងកម្រិតមួយច្រើនជាងប្រាក់បញ្ញើ និងចំនួនប្រាក់ខ្ចីពីទីផ្សារហិរញ្ញវត្ថុនោះការធ្លាក់ចុះនៃអត្រាការប្រាក់នឹងធ្វើឲ្យកម្រិតប្រាក់ចំណេញរបស់ស្ថាប័នកើនឡើងផងដែរ។ ក្នុងករណីនេះចំណូលពីការផ្តល់កម្ចីនឹងធ្លាក់ចុះលឿនជាង ចំណាយលើការប្រាក់របស់ប្រាក់បញ្ញើ និងប្រាក់ខ្ចីពីទីផ្សារហិរញ្ញវត្ថុ។

**គ. ហានិភ័យអត្រាប្តូរប្រាក់( Exchange Rate Risk )**

ហានិភ័យអត្រាប្តូរប្រាក់ គឺជាហានិភ័យបង្ករឡើងដោយស្ថាប័នហិរញ្ញវត្ថុដែលបានធ្វើប្រតិបត្តិការទិញនិងលក់ រូបិយប័ណ្ណបរទេស។ តម្លៃរូបិយប័ណ្ណបរទេសដែលគេទិញឬលក់នៅក្នុងប្រតិបត្តិការទីផ្សាររូបិយប័ណ្ណបរទេស ប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ចទីផ្សារប្តូរប្រាក់។ ស្ថាប័នដែលទិញ ឬលក់រូបិយប័ណ្ណទាំងនេះ អាចប្រឈមមុខនឹងការខាតបង់ ដោយសារការប្រែប្រួលទាំងអត្រាទិញ ឬលក់រូបិយប័ណ្ណទាំងនេះក្នុង ទីផ្សាររូបិយប័ណ្ណបរទេស។

**ឃ. ហានិភ័យទីផ្សារ( Market Risk )**

ហានិភ័យទីផ្សារ គឺជាហានិភ័យដែលកើតឡើង នៅពេលដែលស្ថាប័នហិរញ្ញវត្ថុ ធ្វើសកម្មភាពទិញនិងលក់ទ្រព្យសកម្ម ឬសញ្ញាប័ណ្ណក្នុងរយៈពេលខ្លីជាជាងការស្តុកទុក ក្នុងគោលបំណងធ្វើការវិនិយោគការផ្តល់ប្រាក់កម្ចី ឬការទិញហ៊ុនទុកលក់រយៈពេលវែង។ ហានិភ័យនេះមានទំនាកទំនងជាមួយហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់។ នៅពេលដែលហានិភ័យទាំងនេះ មានការកើនឡើង ឬធ្លាក់ចុះហានិភ័យដែលកើតឡើងនៅក្នុងស្ថាប័នហិរញ្ញវត្ថុទាំងអស់ ទទួលរងនូវផល

ប៉ះពាល់យ៉ាងខ្លាំង។ ម៉្យាងវិញទៀតហានិភ័យទីផ្សារ កើតឡើងនៅពេលអត្រាការប្រាក់ឡើងខ្ពស់ជាងតំលៃទីផ្សារនៃសញ្ញាប័ណ្ណ ដែលស្ថាប័នហិរញ្ញវត្ថុបានទិញកាលពីមុននឹងធ្លាក់ចុះដែលធ្វើឲ្យស្ថាប័នជាច្រើនមានការខាតបង់ក្នុងការលក់សញ្ញាប័ណ្ណទាំងនោះ។ ផ្ទុយមកវិញ នៅពេលដែលអត្រាការប្រាក់ធ្លាក់ចុះ នោះតម្លៃសញ្ញាប័ណ្ណនឹងកើនឡើង ដែលនាំឲ្យមានផលចំណេញ នៅពេលដែលស្ថាប័នហិរញ្ញវត្ថុលក់សញ្ញាប័ណ្ណទាំងនោះ។

**ង. ហានិភ័យសន្ទនីយភាព** (Liquidity risk)

ហានិភ័យសន្ទនីយភាព គឺជាហានិភ័យដែលកើតឡើងបណ្តាលមកពី ការខ្វះខាតសាច់ប្រាក់ក្នុងការបង្វែរឲ្យអតិថិជនដែលមកដកប្រាក់បញ្ញើ និងប្រាក់ស្នើសុំពីអតិថិជនល្អៗទាន់ពេលវេលា ដែលជាហេតុធ្វើឱ្យស្ថាប័នបាត់បង់អតិថិជននិងផលចំណេញជាច្រើន។ នៅពេលដែលស្ថាប័នគ្មានលទ្ធភាពបំពេញតម្រូវការសាច់ប្រាក់របស់ខ្លួនតាមថ្លៃដើម ដ៏សមស្របមួយនោះទេ ជាសញ្ញាដំបូងបង្ហាញថាស្ថាប័ននឹងជួបប្រទះនូវបញ្ហាយ៉ាងធ្ងន់ធ្ងរ។

**ច. ហានិភ័យសាធនភាព** (Solvency risk)

ហានិភ័យសាធនភាព គឺជាហានិភ័យដែលកើតឡើង នៅពេលដែលស្ថាប័ហិរញ្ញវត្ថុមួយមិនអាចមានមូលធនគ្រប់គ្រាន់ ដើម្បីធ្វើការទូទាត់នូវការធ្លាក់ចុះ យ៉ាងឆាប់រហ័សនៃតម្លៃទ្រព្យសកម្មរបស់ស្ថាប័ន។ ប្រសិនបើស្ថាប័នហិរញ្ញវត្ថុមានឥណទានទារមិនទាន់បានច្រើនពេក ឬប្រសិនបើតម្លៃទីផ្សារនៃសញ្ញាប័ណ្ណជាច្រើន ដែលស្ថាប័នហិរញ្ញវត្ថុបានវិនិយោគធ្លាក់ចុះ ដែលធ្វើឲ្យមានការខាតបង់ច្រើន នោះគណនីមូលធន នឹងត្រូវនូវរងសម្ពាធយ៉ាងធ្ងន់ធ្ងរដោយស្រូបយកការខាតបង់ទាំងនោះ។ ប្រសិនបើវិនិយោគិន និងអ្នកផ្ញើប្រាក់បានដឹងពីបញ្ហានេះ នោះគេនឹងចាប់ផ្តើមដកប្រាក់របស់គេទៅវិញ ពេលនោះអ្នកគ្រប់គ្រងគ្មានមធ្យោបាយណាក្រៅពីប្រកាសថា គ្មានលទ្ធភាពសងបំណុលបាន ហើយនឹងបិទទ្វារជាបណ្តោះ អាសន្ន។

**២. ហានិភ័យប្រតិបត្តិការ**( Operational Risk)

**ក.ហានិភ័យបច្ចេកវិជ្ជា**(Technology Risk)

អ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុទាំងឡាយ ជានិច្ចកាលតែងតែប្រឈមមុខនឹងហានិភ័យច្ចេកវិទ្យាដែលមានការខូចខាតបណ្តាលមកពីកត្តាអាកាសធាតុ កត្តាអាយុកាល ឬកំហុសដែលបណ្តាលមកពីប្រព័ន្ធកុំព្យូទ័រមានចន្លោះប្រហោងក្នុងការត្រួតពិនិត្យគុណភាពការងារអេសមត្ថភាពក្នុងការផលិតនិងផ្តល់សេវាកម្ម បាតុភូតធម្មជាតិ សកម្មភាពភេរវកម្ម កំហុសផ្សេងៗរបស់អ្នកគ្រប់គ្រងក្នុងការសម្រេចចិត្តលើកិច្ចការអ្វីមួយ ការប្រែប្រួលនៃសេដ្ឋកិច្ច ដែលជះឥទ្ធិពលដល់តម្រូវការសម្រាប់សេវាកម្មផ្នែកហិរញ្ញវត្ថុផ្សេងៗ។ ការប្រែប្រួលទាំងនេះអាចមានឥទ្ធិពលយាងអាក្រក់ដល់លំហូរចំណូលថ្លៃដើមនៃប្រតិបត្តិការ និងតម្លៃនៃការវិនិយោគរបស់ម្ចាស់ស្ថាប័ន។

**ខ. ហានិភ័យយុទ្ធសាស្ត្រ**(Strategic Risk)

ការប្រែប្រួលក្នុងការរកចំណូល ដោយសារការសម្រេចចិត្តទៅលើការធ្វើ អាជីវកម្មមិនល្អ ការអនុវត្តន៍នៃការសម្រេចចិត្តមិនបានសមរម្យ ខ្វះការទទួលខុសត្រូវ ដើម្បីធ្វើការផ្លាស់ប្តូរឧស្សាហាកម្ម។ ហានិភ័យយុទ្ធសាស្ត្រកើតចេញពីលក្ខណៈដូចជាផ្នែកធនធានមនុស្សនៅក្នុងការគ្រប់គ្រងលើការសម្រេចចិត្តរយៈពេល

វែងមិនបានល្អ ដែលឆ្លុះបញ្ចាំងឲ្យឃើញថា ការកំណត់ពេលវេលាមិនបានត្រឹមត្រូវ ខ្វះការយល់ដឹង ខ្វះការតស៊ូ និងខ្វះការតាំងចិត្ត ដើម្បីទទួលបាននូវភាពជោគជ័យ។

**គ. ហានិភ័យឧក្រិដ្ឋកម្ម (Criminal risk)**

ហានិភ័យឧក្រិដ្ឋកម្ម គឺជាប្រភេទហានិភ័យដែលបណ្តាលមកពីនិយោជិត ឬប្រធានស្ថាប័ន ធ្វើការកេងប្រវ័ញ្ចឬក្លែងបន្លំទ្រព្យសម្បត្តិរបស់ស្ថាប័ន ដែលអាចធ្វើឱ្យស្ថាប័នចុះខ្សោយ ហើយក្នុងករណីនេះ វាអាចបណ្តាលឲ្យស្ថាប័ន ក្ស័យធនក៏មាន។

**ឃ.ការខូចខាត់ចំពោះទ្យព្យសកម្មជារូបវ័ន្ត(Damage to physical assets)**

ការខូចខាត់ចំពោះទ្យព្យសកម្មជារូបវ័ន្ត គឺជាហានិភ័យដែលកាត់បន្ថយតម្លៃរបស់ទ្រព្យសកម្មរបស់អង្គភាពធុរកិច្ចមួយ ដោយសារតែការខូចខាតទ្រព្យសម្បត្តិពិតដូចជា អគ្គីសភ័យ ចោរកម្ម គ្រោះធម្មជាតិ ប្រធានស័ក្តិ និងការដកសិទ្ធិ ឬអាជ្ញាប័ណ្ណអាជីវកម្មដោយរដ្ឋាភិបាល។

**៣. ហានិភ័យធុរកិច្ច(Business Risk)**

**ក. ហានិភ័យកេរ្តិ៍ឈ្មោះ (Reputation risk)**

ហានិភ័យកេរ្តិ៍ឈ្មោះ គឺជាហានិភ័យកើតឡើងមកពីភាពមិនច្បាស់លាស់ដែលទាក់ទងនិងគំនិតរបស់សាធារណៈជនដូចជាការយល់ខុសដោយមិនដឹងថាវាពិត ឬមិនពិតក៏ដោយ ក៏អាចជះឥទ្ធិពលអាក្រក់ដល់ការរកចំណូលរបស់ស្ថាប័នហិរញ្ញវត្ថុដែរ ដោយជំរុញឲ្យម្ចាស់បំណុល និងអតិថិជនដ៏ទៃទៀតមិនមានជំនឿលើស្ថាប័ននោះ។




Concept for risk management in a flowchart presentation

**ខ. ហានិភ័យប្រទេស (Country risk)**

ហានិភ័យប្រទេសគឺជាហានិភ័យដែលកើតឡើងដោយសារការសងប្រាក់ត្រឡប់ឲ្យទៅម្ចាស់បំណុលឬវិយោគិនបរទេសអាចនឹងត្រូវបានរាំងដោយសារតែ មានការដាក់កំហិតការអន្តរាគមន៍ ឬការជ្រែតជ្រែកពីសំណាក់រដ្ឋាភិបាលប្រទេសនោះ។

គ. ហានិភ័យច្បាប់ (Legal risk)

ហានិភ័យច្បាប់ គឺជាហានិភ័យកើតឡើងនៅក្នុងប្រព័ន្ធច្បាប់ ដូចជាប្រព័ន្ធតុលាការខ្សោយ គ្មាននីតិរដ្ឋកិច្ចសន្យាដែលពុំអាចបង្ខំឲ្យប្រតិបត្តិបានរឿងក្តីឬការកាត់ក្តីមិនយុត្តិធម៌អាចកាត់បន្ថយចំណូល និងបង្កើនការចំណាយរបស់ស្ថាប័នហិរញ្ញវត្ថុ។

**៤. ហានិភ័យព្រឹត្តិការណ៍**( Event Risk)

ក. ហានិភ័យនយោបាយ

ហានិភ័យនយោបាយ គឺជាបម្រែបម្រួលនយោបាយ ឬរចនាសម្ព័ន្ធនយោបាយរបស់ប្រទេសមួយដូចជាច្បាប់ពន្ធ ពន្ធនាំចូល ការដកហូតទ្រព្យសកម្ម ឬ ការដាក់កំហិតលើការយកប្រាក់ចំណេញចេញពីប្រទេសកំពុងវិនយោគ។

**ខ.វិបត្តិមីក្រូហិរញ្ញវត្ថុ**(Microfinance Crises)

វិបត្តិមីក្រូហិរញ្ញវត្ថុមួយ គឺជាវិបត្តិហិរញ្ញវត្ថុមួយដែលប៉ះពាល់ទៅដល់សកម្មភាពធនាគារ។ វិបត្តិមីក្រូហិរញ្ញវត្ថុរួមមានប្រតិបត្តិការរបស់មីក្រូហិរញ្ញវត្ថុដែលប៉ះពាល់ដល់មីក្រូហិរញ្ញវត្ថុតែមួយ និងវិបត្តិជាប្រព័ន្ធកើតឡើងនៅក្នុងប្រទេសមួយ ដែលធ្វើឲ្យស្ថាប័នហិរញ្ញវត្ថុប្រឈមនឹងផលវិបាកជាច្រើននៅក្នុងការទូទាត់កិច្ចសន្យា។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

តាមការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តការងារជាក់ស្តែង គឺជាការវិភាគដែលមានសារៈសំខាន់បំផុតក្នុងការវាយតម្លៃវាស់វែងពីដំណើរការ និងសកម្មភាពរបស់អង្គភាព ដើម្បីឱ្យអង្គភាពបានដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ហើយចេះកែប្រែចំណុចខ្សោយរបស់ខ្លួនឱ្យទៅជាចំណុចខ្លាំង ពេលនោះក្រុមហ៊ុននិងមានការរីកចម្រើនទៅមុខៗ។ បន្ទាប់ពីបានសិក្សាស្រាវជ្រាវមួយរយៈពេលកន្លងមក ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតយើងបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដូចជា ៖

## ៤.១ ការវិភាគលើចំណុចខ្លាំងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

- ការបើកគណនីរបស់មីក្រូហិរញ្ញវត្ថុអម្រឹតមានភាពងាយស្រួល និងរហ័សទាន់ចិត្តជូនអតិថិជន។
- ផ្តល់នូវអត្រាការប្រាក់ខ្ពស់រហូតទៅដល់១០% នៅពេលអតិថិជនមានការដាក់ប្រាក់បញ្ញើសន្សំ។
- បានគិតគូរដល់វិស័យអប់រំពិសេសជួយសម្រួលដល់ក្មេងៗដោយបានបង្កើតនូវគណនីប្រាក់បញ្ញើសន្សំដែលជាគណនីក្មេងឆ្លាត។
- មានតម្កល់ប្រាក់នូវធនាគារជាតិនៃកម្ពុជាត្រឹមត្រូវ និងស្របតាមច្បាប់របស់ធនាគារជាតិកម្ពុជា។
- គណនីប្រាក់បញ្ញើមានការបែងចែកច្បាស់លាស់ និងមានគោលដៅកំណត់ជាក់លាក់ចំពោះអតិថិជន។
- អតិថិជនអាចដាក់ប្រាក់បញ្ញើដោយមិនបាច់ព្រួយបារម្ភពីសុវត្ថិភាពរបស់សាច់ប្រាក់ឡើយ។
- អតិថិជនអាចទូទាត់សាច់ប្រាក់តាមរយៈគណនីអម្រឹតបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។
- រួមចំណែកពីលើនេះ លោកអ្នកដែលជាអតិថិជនរបស់អម្រឹត អាចដក់ប្រាក់បានដោយងាយស្រួលនៅតាមរយៈទូរ ATM របស់អម្រឹតដែលនៅជិតផ្ទះរបស់លោកអ្នកបាន។

## ៤.២ ការវិភាគលើចំណុចខ្សោយរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

ទោះបីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ទទួលបានភាពរីកចម្រើនលើសេវាកម្មប្រាក់បញ្ញើរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយនេះ ពុំទាន់ទទួលបាននូវភាពជោគជ័យទាំងស្រុងនៅឡើយទេ។ ទន្ទឹមនឹងចំណុចខ្លាំងដែលបានរៀបរាប់ខាងលើនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតក៏មាននូវចំណុចខ្សោយមួយចំនួនតូចផងដែរ ដូចជា ៖

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត មិនទាន់អាចបង្កើននូវភាពទូលំទូលាយសម្រាប់ផ្តល់ជូនដល់អតិថិជនបានឡើយ ដោយហេតុថានៅតាមទីជនបទមួយចំនួនមិនមាននូវការផ្សព្វផ្សាយ ក៏ដូចជាទូរ ATM សម្រាប់ផ្តល់ជូនសេវាកម្មដល់អតិថិជននោះទេ។
- ប្រសិនអតិថិជនចង់ដកប្រាក់ លុះត្រាតែអតិថិជនធ្វើដំណើរទៅទីរួមខេត្តឯណោះ ដែលផ្តល់ដល់ការលំបាកដល់អតិជន។
- ចំណែកសេវាប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ក៏មិនមានមានភាពទូលំទូលាយ សម្រាប់អតិថិជនដែលរស់នៅជនបទឡើយ។

- ទោះបីការគ្រប់គ្រងប្រាក់បញ្ញើមានលក្ខណៈត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏ប៉ុន្តែការគ្រប់គ្រងនេះនៅតែមានកម្រឹតនៅឡើយ។ ទោះបីតារាងសមិទ្ធផលប្រាក់បញ្ញើមានលក្ខណៈត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏ប៉ុន្តែការគ្រប់គ្រងនេះនៅតែមានកម្រឹតនៅឡើយ។ ដោយតារាងសមិទ្ធផលប្រាក់បញ្ញើក្នុងឆ្នាំ ២០២៤ នេះអាចបញ្ជាក់ឱ្យឃើញថា ចំនួនគណនីប្រាក់បញ្ញើពុំសូវមានការកើនឡើងច្រើននោះទេ ដោយសារការប្រកួតប្រជែងផ្នែកទីផ្សាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតនៅមានកម្រឹតនៅឡើយ បើប្រៀបធៀបជាមួយដៃគូប្រកួតប្រជែងផ្សេងទៀត។
- ចំពោះគណនីប្រាក់បញ្ញើក្មេងឆ្លាតបានកំណត់រយៈពេល ដែលអាចឱ្យឪពុកម្តាយរបស់ពួកគេដាក់ប្រាក់សន្សំបាន ត្រឹមតែកូនរបស់ពួកគេរៀនថ្នាក់ទី១០ចុះក្រោម ដោយមិនបានគិតទៅលើការសិក្សាបន្តថ្នាក់ហាវិទ្យាល័យនោះទេ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើនខែកន្លងមក កាលពីមុនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតគ្រាន់តែជាប្រភេទអង្គការក្រៅរដ្ឋាភិបាលតែប៉ុណ្ណោះបន្ទាប់មកបានទទួកអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា "ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ" ។ នៅឆ្នាំ២០០១ ដោយសារមានការខិតខំប្រឹងប្រែងជាខ្លាំងទើបធ្វើឱ្យគ្រឹះស្ថានទទួលបានជោគជ័យលើវិស័យហិរញ្ញវត្ថុនេះ និងបានវិវត្តន៍ខ្លួនយ៉ាងឆាប់រហ័ស ហើយទាន់សម័យកាលថែមទាំងមានការគាំទ្រពីសំណាក់ប្រជាជនកម្ពុជា ព្រមទាំងរាជរដ្ឋាភិបាលទៀតផង។ អម្រឹតមានសេវាកម្មហិរញ្ញវត្ថុជាច្រើន មានទាំងឥណទាន មានទាំងសេវាទទួលប្រាក់បញ្ញើ សម្រាប់បម្រើជូនដល់ប្រជាជនកម្ពុជា ដែលជាការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើន។ ជាពិសេសនោះគឺ ជួយគាំទ្រទៅដល់ការសិក្សា បង្កើនធនធានមនុស្សនៅកម្ពុជាឱ្យមានភាពសម្បូរបែប និងធ្វើឱ្យប្រជាជនយើងសម្បូរទៅដោយអ្នកដែលមានចំណេះដឹងច្រើន។

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ មួយរយៈកន្លងមកទៅលើប្រធានបទ "នីតិវិធីនៃការទទួកប្រាក់បញ្ញើរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុអម្រឹត" ដូច្នេះយើងអាចសន្និដ្ឋានបានថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពិតជាមានភាពខ្លាំងទៅលើវិស័យហិរញ្ញវត្ថុ ជាពិសេសនោះគឺសេវាទទួលប្រាក់បញ្ញើសន្សំ ដែលទទួលបានការគាំទ្រពីបណ្តាអតិថិជនទូទាំងប្រទេស ដោយសារការដាក់ប្រាក់បញ្ញើមានលក្ខណៈងាយស្រួល សុវត្ថិភាព អត្រាការប្រាក់ខ្ពស់ និងទទួកបានផលចំណេញច្រើន។ លើសពីនេះគណនីនីមួយៗមានការបែងចែកពីគោលបំណងច្បាស់លាស់ក្នុងការដាក់សន្សំ ដើម្បីឱ្យអតិថិជនសម្រេចនៅគោលដៅដែលបានកំណត់ទៅលើគណនីទាំងអស់ (គណនីប្រាថ្នា គណនីមានការកំណត់ គណនីក្មេងឆ្លាត)។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវអំពីប្រធានបទខាងលើ បានបង្ហាញឱ្យឃើញពីចំណុចល្អជាច្រើននៅក្នុងគ្រឹះស្ថានហើយក៏មាននូវចំណុចខ្វះខាតខ្លះៗផងដែរ។ ក្រុមយើងខ្ញុំសូមផ្តល់ជាមតិយោបល់ និងអនុសាសន៍មួយចំនួន ក្នុងន័យស្ថាបនាកែលម្អនៅចំណុចខ្វះខាតទាំងនោះ ដើម្បីឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតទទួលបានការដាក់ប្រាក់បញ្ញើពីអតិថិជនកាន់តែច្រើន និងមានការរីកចម្រើនជាងមុន។

- ប្រសិនជាអាចគណនីក្មេងឆ្លាត អាចដាក់ប្រាក់សន្សំចាប់ពីក្រោមឧត្តមសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សានិងមានបែងចែកជាកញ្ចប់ គឺកញ្ចប់សម្រាប់ថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យ។ ករណីគ្រួសារខ្លះ មានជីវភាពខ្វះខាតហើយសាលាឆ្ងាយ និងកូនៗត្រូវការរៀនគួរច្រើននៅថ្នាក់វិទ្យាល័យដើម្បីត្រៀមប្រឡងបាក់ឌុប ដូច្នេះ បើគណនីក្មេងឆ្លាតមានជាកញ្ចប់សម្រាប់ថ្នាក់វិទ្យាល័យ នោះគឺជួយសម្រួលដល់ការសិក្សារបស់ក្មេងៗ និងកាត់បន្ថយការឈប់រៀនដោយសារកត្តាជីវភាព។

- ចំពោះគណនីប្រថ្នា គួរតែបង្កើនការផ្សព្វផ្សាយទាក់ទង និងគណនីនេះឱ្យបានច្រើនតាមដែលអាចធ្វើបាន តាមរយៈបណ្តាញសង្គមក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដើម្បីឱ្យអតិថិជនយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍នៃគណនីប្រាថ្នា។ ដោយសារតែគណនីនេះទទួលបានអត្រាការប្រាក់ខ្ពស់ កំណត់គោលដៅសន្សំច្បាស់លាស់ ផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការសន្សំ (គោលបំណងថ្ងៃអនាគត)។ ប៉ុន្តែ បើការផ្សព្វផ្សាយទាក់ទងនិងគណនីនេះពុំសូវមាន គឺវាអាចធ្វើឱ្យបាត់បង់នូវអតិថិជនប្រើប្រាស់សេវាកម្មនេះ។
- ដើម្បីឱ្យការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត គួរតែបង្កើនការផ្សព្វផ្សាយទាក់ទងទៅនឹងផលិតផលដែលខ្លួនមានជូនដល់អតិថិជន និងបង្កើនវិធីសាស្ត្រថ្មីៗ ដើម្បីទាក់ទាញអតិថិជនឱ្យមកទទួលសេវាប្រាក់បញ្ញើរកាន់តែច្រើន តាមរយៈការបង្កើតកម្មវិធីចាប់រង្វាន់លើកទឹកចិត្ត ថែមទាំងបង្កើន ក៏ដូចជាការបង្កើតគ្រឹះស្ថានបន្ថែមនៅតាមទីជនបទ ដើម្បីផ្តល់នូវភាពងាយស្រួលជូនដល់អតិថិជន។

# ឯកសារយោង


1. រៀបរៀងដោយនិស្សិត យន សុខលីម, ហេង គីមហៀក, ស៊ីន រិះ, នួន សីហា. (២០២៣). *នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី២០. វិទ្យស្ថាន វ៉ាន់ដា. ភ្នំពេញ។
2. Microfinance institution. *គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ. Retrieved from* June, 12 2025 from https://developers.bri.co.id/en/node/51155
3. Khem Sarith. (October 2016). *ការគ្រប់គ្រងហិរញ្ញវត្ថុអន្តរជាតិ. Retrieved from* June, 12 2025 from https://khemsarith.wordpress.com/2016/10/
4. Developers. (2023). *ប្រាក់បញ្ញើ.* Retrieved June, 13 2025 from https://developers.bri.co.id/en/node/51155
5. SME Bank. (2022, November 4). គណនីបញ្ញើសន្សំ. Retrieved June 15 2025 from https://www.smebankcambodia.com.kh/km-kh/saving-account/
6. Facebook page. Kanann Neam-Law. (Mar.13.2022). *នីតិ.* Retrieved June, 15 2025 from https://www.facebook.com/share/1AbtcvqwgP/
7. Facebook page. Kanan Neam-Law. (Jun.27.2022) *នីតិ* Retrieved June, 15 2025 from https://www.facebook.com/share/p/16MTirjBRx/
8. Amret. *ប្រវត្តិអម្រឹត.* Retrieved (June, 15 2025) from https://www.amret.com.kh/kh/about-amret
9. Khem Sarith. (2016, October 12). *សេវាកម្មមិនអនុញ្ញាតចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ.* Retrieved June, 16 2025 from https://khemsarith.wordpress.com/2016/10/12/
10. Amret. (2025). *ប្រាក់បញ្ញើមានកាលកំណត់.* Retrieved June, 16 2025 from https://www.amret.com.kh/kh/Fixed-Deposit-Account
11. Amret. (2025). *គណនីក្មេងឆ្លាត.* Retrieved June, 16 2025 from https://www.amret.com.kh/kh/kmen-chhlat-account
12. Amret. (2025). *គណនីប្រាថ្នា.* Retrieved June, 18 2025 from https://www.amret.com.kh/kh/goal-account
13. Amret. (2025). *គណនី Flexi.* Retrieved June, 16 2025 from https://www.amret.com.kh/kh/flexi-term-deposit
14. Amret. (2025). *គណនីចម្រើន.* Retrieved June, 20 2025 from https://www.amret.com.kh/kh/Chamroeun-Account-new

# ឧបសម្ព័ន្ធ




រូបភាពទី១: សំណង់អគារ ការិយាល័យកណ្ដាល



ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថាន វ៉ាន់ដា

សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ
ជំនាញ គណនេយ្យ

ប្រធានបទ៖ នីតិវិធីនៃការទទួលប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត

TOPIC: DEPOSITORY PROCEDURE OF AMRET MICROFINANCE INSTITUTION

រៀបរៀងដោយនិស្សិត៖ ១-និស្សិត យន សុខលីម VI20/013
២-និស្សិត [illegible] VI20/012
៣-និស្សិត [illegible] VI20/026
៤-និស្សិត [illegible] VI20/024

016.274
មេក្រុម យន សុខលីម
VIA.PP/2023

[illegible]

និស្សិតជំនាន់ទី២០

រាជធានីភ្នំពេញ - ឆ្នាំ២០២៣

PHNOM PENH-2023

រូបភាពទី២: សាណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ និស្សិតជំនាន់ទី២០